(๑๗๗) ន កប្បយន្តិ ន បុរេក្ខរោន្តីតិ កប្បាតិ

ទ្វេ កប្បា តណ្ហាកប្បោ ច ទិដ្ឋិកប្បោ ច ។

កតមោ តណ្ហាកប្បោ ។ យាវតា តណ្ហាសង្ខាតេន

សីមកតំ មរិយាទិកតំ ឋិតិកតំ បរិយន្តិកតំ

បរិក្ខេបិតំ មមាយិតំ ឥទំ មមំ ឯតំ មមំ ឯត្តកំ មមំ

ឯត្តាវតា មម មម វត្ថុ សន្តា តត្ថ រសោ ជោដ្ឋា

អគ្គរណោ ចាបុរណោ ទាសីទាសោ អជេឡកោ កុក្កុ-

ដសូករោ ហត្ថិគវាស្សវឡវោ ខេត្តំ វត្ថុ ហិរញ្ញំ សុ-

វណ្ណំ តាមជាតមរជជាទិយោ រជ្ជញ្ច ជនបទោ ច កោ-

សោ ច កោដ្ឋាគារញ្ច កេវលម្បិ មហាបឋវឹ តណ្ហា-

វសេន មមាយតិ យាវតា អដ្ឋសតតណ្ហាវិចរិតំ អយំ

តណ្ហាកប្បោ ។

កតមោ ទិដ្ឋិកប្បោ ។ វីសតិវត្ថុកា សក្កាយទិដ្ឋិ

ទសវត្ថុកា មិច្ឆាទិដ្ឋិ ទសវត្ថុកា អន្តគ្គាហិកា ទិដ្ឋិ-

យា ឋវត្ថុកា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ

ព្រាហ្មណ៍ មិនមែនស៊ីលវត្ត ដឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញឡើយ ។

(១៧៧) អធិប្បាយពាក្យថា មិនតែងតាំង មិនឆ្លើឲ្យជាប្រជាន ត្រង់ពាក្យថា តែងតាំង បានដល់ ការតែងតាំង ២ គឺការតែងតាំងគឺតណ្ហា ១ ការតែងតាំងគឺទិដ្ឋិ ១ ។

ការតែងតាំងគឺតណ្ហា តើដូចម្តេច ។ ការកំណត់ដែន កំណត់ទឹក កំណត់ផ្លូវ កំណត់ដោយដុំវិញ ហួងហែង អាល័យ ដោយចំណែកតណ្ហា ពាំងប៉ុន្មានថា នេះរបស់អញ នុ៎ះរបស់អញ ប៉ុណ្ណោះរបស់អញ ពាំងប៉ុណ្ណោះ របស់អញ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ របស់អញ គ្រឿងកម្រាល គ្រឿងស្បែកពាក់ ខ្ញុំស្រី ខ្ញុំប្រុស ពពែ ចៀម មាន់ ជ្រូក ដំរី គោ សេះ លា ស្រែ ចម្ការ ច្រាក់ មាស ស្រុក និគម រាជធានី ដែន ជនបទ បន្ទាយ ឃ្លាំង របស់អញ បុគ្គលប្រកាន់ដែនដីពាំងអស់ ដោយអំណាចតណ្ហា តណ្ហាវិបរីត ១០៨ ពាំងប៉ុន្មាន នេះការតែងតាំងគឺតណ្ហា ។

ការតែងតាំង គឺទិដ្ឋិ តើដូចម្តេច ។ សក្កាយទិដ្ឋិ មានវត្ថុ ២០ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ អន្តគ្គាហិកទិដ្ឋិ មានវត្ថុ ១០ ទិដ្ឋិដំណើរ គឺទិដ្ឋិ ការសាំញ៉ាំ គឺទិដ្ឋិ ថ្លូវលំបាក គឺទិដ្ឋិ

นิฏฺฐิสฺส กายิกา นิฏฺฐิปฺปฏิสนฺถารา นิฏฺฐิสญฺโญชนสฺส ตาเยา
ปฏิปฺปสฺสทฺธิยา อกิตฺติยา อวณฺณสฺส อกุสฺสลสฺส มิจฺฉา-
ปโถ มิจฺฉตฺตํ ตสฺสายตนสฺส วิปริเยสคฺคาโหา วิปรีต-
คฺคาโหา วิปลฺลาสคฺคาโหา มิจฺฉาตาโหา อยาถาวกสฺมึ
ยาถาวกนฺติ ตาโหา ยาวตา ทฺวาสฏฺฐิ นิฏฺฐิคตานิ
อยํ นิฏฺฐิกปฺปา ฯ

เตสํ ตณฺหากปฺปา ปหีนา นิฏฺฐิกปฺปา ปฏิ-
นิสฺสฏฺโฐ ตณฺหากปฺปสฺส ปหีนตฺตา นิฏฺฐิกปฺปสฺส
ปฏินิสฺสฏฺฐตฺตา ตณฺหากปฺโป นิฏฺฐิกปฺโป น กปฺปนฺติ
น ฉินฺทนฺติ น สญฺฉินฺทนฺติ น นิกฺกฑฺฒนฺติ ตาหิ นิกฺกฑฺฒนาหิ
น กปฺปยนฺติ ฯ

น ปุเรกฺขาเรนาติ ปุเรกฺขาราติ ทฺเว ปุเรกฺขารา ตณฺหา-
ปุเรกฺขาโร จ นิฏฺฐิปุเรกฺขาโร จ ฯ เปฯ อยํ ตณฺหา-
ปุเรกฺขาโร ฯ เปฯ อยํ นิฏฺฐิปุเรกฺขาโร ฯ เตสํ
ตณฺหาปุเรกฺขาโร ปหีนา นิฏฺฐิปุเรกฺขาโร ปฏินิสฺสฏฺโฐ

ចម្រូងគឺទិដ្ឋិ សេចក្តីអួនអន្លែងគឺទិដ្ឋិ ការប្រកបព្រមគឺទិដ្ឋិ ការកាន់ការទទួល ការប្រកាន់ ការស្អាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពខុស កំពង់នឹងអណ្តូង ការកាន់យកដោយការស្វែងរកខុស ការកាន់យកវិបរីតការកាន់យកវិបល្លាស ការកាន់យកខុស ការកាន់យកក្នុងវត្ថុមិនពិតថាជាសភាពពិត ទិដ្ឋិ ๖๒ ទាំងប៉ុន្មាន ណា មានសភាពយ៉ាងនេះ នេះការតែងតាំងគឺទិដ្ឋិ ។

ការតែងតាំងគឺតណ្ហា ព្រះអរហន្តទាំងនោះ លះបង់ហើយ ការតែងតាំងគឺទិដ្ឋិ លោកលាស់ចោលហើយ ព្រះអរហន្តទាំងឡាយ មិនតែងតាំង មិនឲ្យកើត មិនឲ្យកើតព្រម មិនបង្កើត មិនបង្កើតចំពោះនូវការតែងតាំងគឺតណ្ហា ឬនូវការតែងតាំងគឺទិដ្ឋិ ព្រោះលោកលះបង់ការតែងតាំងគឺតណ្ហា លាស់ចោលការតែងតាំងគឺទិដ្ឋិហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនតែងតាំង ។

ពាក្យថា ការធ្វើឲ្យជាប្រធាន ក្នុងបទថា មិនធ្វើឲ្យជាប្រធាន បានដល់ការធ្វើឲ្យជាប្រធាន ๒ គឺការធ្វើឲ្យជាប្រធានគឺតណ្ហា ๑ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ๑ ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺតណ្ហា ។ បេ ។ នេះ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ ។ ការធ្វើឲ្យជាប្រធានគឺតណ្ហា ព្រះអរហន្តទាំងនោះលះបង់ហើយ ការធ្វើឲ្យជាប្រធានគឺទិដ្ឋិ លោកលាស់ចោលហើយ ព្រះអរហន្តទាំងនោះ មិនធ្វើតណ្ហានឹងទិដ្ឋិ ឲ្យជាប្រធានហើយប្រព្រឹត្ត

តណ្ហាបុរេក្ខារសប្ប បមាទត្តា ឧដ្ឋិបុរេក្ខារសប្ប បដិ-
ឧសប្បដ្ឋត្តា ឧ តណ្ហាំ ឯ ឧដ្ឋឺ ឯ បុរតោ កត្វា ចរន្តិ
ឧ តណ្ហាឆជា ឧ តណ្ហាកេតុ ឧ តណ្ហាធិបតេយ្យា
ឧ ឧដ្ឋិដ្ឋជា ឧ ឧដ្ឋិកេតុ ឧ ឧដ្ឋាធិបតេយ្យា ឧ
តណ្ហាយ ឯ ឧដ្ឋិយា ឯ បរិវារិតា ចរន្តីតិ ឧ កប្ប-
យន្តិ ឧ បុរេក្ខរោន្តិ ។

(១៧៨) ឆម្ចាបិ តេសំ ឧ បដិច្ចតាសេតិ ឆម្ចា
ផ្ទុន្តិ ទ្វាសដ្ឋឺ ឧដ្ឋិកតានិ ។ តេសន្តិ តេសំ អរហន្តានំ
ខីណាសវានំ ។ ឧ បដិច្ចតាសេតិ សស្សតោ លោ-
កោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឧ បដិច្ចតាសេ
អសស្សតោ លោកោ ។ បេ ។ នេវ ហោតិ ឧ ឧ
ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃ-
មញ្ញន្តិ ឧ បដិច្ចតាសេតិ ឆម្ចាបិ តេសំ ឧ បដិច្ចតាសេ ។

(១៧៩) ឧ ព្រាហ្មណោ សីលវតេន
នេយ្យាតិ ជាតិ បដិក្ខេបោ ។ ព្រាហ្មណោតិ
សត្តន្នំ ឆម្ចានំ ពាហិតត្តា ព្រាហ្មណោ ។ បេ ។

ព្រោះលោកលះបង់ការឆ្លៀវឆ្លាសក្នុងការធ្វើឲ្យជាប្រធានគឺតណ្ហា រលាស់ចោលការឆ្លៀវឆ្លាសក្នុងការធ្វើឲ្យជាប្រធាន គឺទិដ្ឋិ ព្រះអរហន្តខីណាស្រពត់មិនមានតណ្ហា ដូចជាទន់ជ័យ មិនមានតណ្ហាដូចជាទន់ មិនមានតណ្ហាជាអធិបតិ មិនមានទិដ្ឋិដូចជាទន់ជ័យ មិនមានទិដ្ឋិដូចជាទន់ មិនមានទិដ្ឋិជាអធិបតិ គឺតណ្ហានិងទិដ្ឋិមិនប្រព្រឹត្តចោមរោមហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ។

(១៧៨) ទិដ្ឋិ ក្នុងបទថា ធម្មេ ក្នុងបទថា ដ្បិតធម៌ទាំងឡាយលោកមិនទទួលយកទេ ។ ពាក្យថា លោក គឺព្រះអរហន្តខីណាស្រពត់នោះ ។ ពាក្យថា មិនទទួលយកទេ គឺមិនទទួលថា លោកទៀង ពាក្យនេះពិត ពាក្យដទៃជាមោឃៈ មិនទទួលថា លោកមិនទៀង ។ បេ ។ សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏ទេ មិនកើតទៀតក៏ទេ ពាក្យនេះជាពាក្យពិត ពាក្យឯទៀតជាមោឃៈ ហេតុនោះ (ទ្រង់ត្រាស់ថា) ដ្បិតធម៌ទាំងឡាយ លោកមិនទទួលយកទេ ។

(១៧៩) ពាក្យថា មិនមែន ក្នុងបទថា ព្រាហ្មណ៍មិនមែនសីលវត្តដឹកនាំបានទេ ជាពាក្យហាមឃាត់ ។ ពាក្យថា ព្រាហ្មណ៍ គឺបុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះលោកបន្សាត់បង់នូវធម៌ទាំង ៧ ។ បេ ។

អនិស្សិតោ តាណំ បវុច្ចតេ ស ព្រាហ្មោ ។ ន ព្រាហ្មណោ សីលេវតេន នេយ្យោតិ ព្រាហ្មណោ សីលេន វា វត្តេន វា សីលវត្តេន វា ន យាយតិ ន និយ្យាយតិ ន វុយ្ហតិ ន សំហារីយតីតិ ន ព្រាហ្ម-ណោ សីលវតេន នេយ្យោ ។

(๑๘๐) ចារដ្ឋំ‌តោ ន បច្ចេតិ តានីតិ ចារំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្ពសង្ខារសមថោ សព្ពូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និរោធោ និព្ពានំ ។ យោ ចារគតោ ចារបញ្ញោ អន្តគតោ អន្តបញ្ញោ កោដិគតោ កោដិបញ្ញោ ។ បេ ។ ន តេន តស្ស បុនព្ភវាយ ចារដ្ឋំ‌តោ ។ ន បច្ចេតីតិ សោតាបត្តិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ[1] ន បច្ចាគច្ឆតិ សកទាគាមិមគ្គេន យេ កិលេសា បហីនា តេ កិលេសេ ន បុនេតិ ន បច្ចេតិ ន បច្ចាគច្ឆ-តិ អនាគាមិមគ្គេន យេ កិលេសា បហីនា

---

๑ ម. ន បុន បច្ចេតិ ។

ជាអ្នកមិនអាស្រ័យ (នូវទិដ្ឋិ) ជាតាទិបុគ្គល បុគ្គលនោះ លោកហៅថា ព្រាហ្មណ៍ ។ ពាក្យថា ព្រាហ្មណ៍ មិនមែនសីលវត្ត ដឹកនាំបានទេ បានសេចក្តីថា ព្រាហ្មណ៍គឺសីលឬវត្ត ឬសីលវត្តដឹកនាំមិនបាន នាំទៅមិនបាន បន្សាត់ទៅមិនបាន ទង់ជាញ៉ាទៅមិនបាន ហេតុនោះ (ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ មិនមែនសីលវត្ត ដឹកនាំបានទេ ។

(១៨០) ពាក្យថា លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ អធិប្បាយថា អមតនិព្វាន លោកហៅថា ត្រើយ បានខាងការរម្ងាប់សង្ខារទាំងអស់ ការលះបង់ឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាកវាគៈ ការរលត់ និព្វាន ។ បុគ្គលណា ទៅកាន់ត្រើយដល់ត្រើយ ទៅកាន់ទីបំផុត ដល់ទីបំផុត ទៅកាន់ខាងចុង ដល់ខាងចុង ។ បេ ។ កពង្គីទៀត នៃបុគ្គលនោះ មិនមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយហើយ ។ ពាក្យថា មិនត្រឡប់មកវិញ គឺកិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសោតាបត្តិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយសកទាគាមិមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មករកកិលេសទាំងនោះ វិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអនាគាមិមគ្គ

តេ កាលេសេ ច បុនេតិ ច បដ្ឋេតិ ច បច្ចាភដ្ឋេតិ អរហត្តមគ្គេន យេ កាលេសា បហីនា តេ កាលេសេ ច បុនេតិ ច បដ្ឋេតិ ច បច្ចាភដ្ឋេតីតិ ចារដ្ឋោ ច បដ្ឋេតិ ។ តានីតិ អរហា បញ្ចហាការេហិ តានិ វជ្ឈានិជ្ជេ តានិ ចត្តារីតិ តានិ តិណ្ណាវីតិ តានិ មុត្តារីតិ តានិ តំនិន្ទេសា តានិ ។

កថំ អរហា វជ្ឈានិជ្ជេ តានិ ។ អរហា លាភេបិ តានិ អលាភេបិ តានិ យសេបិ តានិ អយសេបិ តានិ បសំសាយបិ តានិ និន្ទាយបិ តានិ សុខេបិ តានិ ទុក្ខេបិ តានិ ។ ឯកច្ចេ ពាហាំ កន្ទេន លិម្បយ្យុំ ឯកច្ចេ ពាហាំ ឆសិយា តច្ឆយ្យុំ អមុស្មិំ នត្ថិ រាគោ អមុស្មិំ នត្ថិ បដិឃំ អនុនយបដិឃវិប្បហីនោ ទុក្ខាតិដ្ឋាតីវិតិវត្តោ អនុភវនវិភវនសមតិក្កន្តោ ឯវំ អរហា វជ្ឈានិជ្ជេ តានិ ។

លោកមិនត្រឡប់ មិនមក មិនត្រឡប់មក រកកិលេសទាំងនោះវិញទេ កិលេសទាំងឡាយណា ដែលលោកលះបង់ហើយ ដោយអរហត្តមគ្គ លោកមិនត្រឡប់ មិនមក មិនត្រឡប់មក រកកិលេសទាំងនោះវិញទេ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយ ហើយមិនត្រឡប់មកវិញទេ ។ ពាក្យថា ជាអ្នកនឹងធឹង បានដល់ព្រះអរហន្ត លោកនឹងធឹងដោយអាការ ៤ យ៉ាង គឺលោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ ๑ លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ ๑ លោកនឹងធឹង ព្រោះជាអ្នកផ្តាច់ហើយ ๑ លោកនឹងធឹង ព្រោះជាអ្នករួចហើយ ๑ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះ ๑ ។

លោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍ តើដូចម្តេច ។ ព្រះអរហន្ត លោកនឹងធឹងក្នុងលាភ នឹងធឹងក្នុងអលាភ នឹងធឹងក្នុងយស នឹងធឹងក្នុងអយស នឹងធឹងក្នុងសេចក្តីសរសើរ នឹងធឹងក្នុងនិន្ទា នឹងធឹងក្នុងសុខ នឹងធឹងក្នុងទុក្ខ ។ បើពួកជនលាបដៃម្ខាង ដោយគ្រឿងក្រអូប បើពួកជនច្រាសដៃម្ខាងដោយកាំបិត តម្រេកក្នុងការលាបឯណោះក៏មិនមាន សេចក្តីថ្នាំងថ្នាក់ក្នុងការច្រាសឯណោះ ក៏មិនមាន ព្រះអរហន្ត លះបង់ស្រឡះនូវសេចក្តីត្រេកអរនឹងសេចក្តីថ្នាំងថ្នាក់ ប្រព្រឹត្តកន្លងនូវសេចក្តីលើកតំកើងនឹងសេចក្តីផ្ងាញ់ផ្ងាល់ កន្លងផុតនូវសេចក្តីស្រឡាញ់នឹងសេចក្តីស្អប់ហើយ ព្រះអរហន្ត លោកនឹងធឹង ក្នុងឥដ្ឋារម្មណ៍នឹងអនិដ្ឋារម្មណ៍យ៉ាងនេះ ។

กตมํ อารมฺมณตฺตายเ ญาณํ ฯ อารมฺมณเตา ก-
เตา จตฺตาโร ขนฺธา มุตฺตา ปหีนา ปฏินิสฺสฏฺฐา ฯ
นิพฺพานญฺจ เหวเหตุ ขุปฺปนาเหตุ มคฺคา
ปฏิปทาเสา ฉสฺสุ ผสฺเสสุ ผุฏฺฐายเ เวทนายเ
สาเหยฺยา ชาตฺยา สาราเคา อตฺถิตาเคา ภเวา ภเว
กามเลาเสา สเพฺพ ทุจฺจริตา สเพฺพ ทรถา สเพฺพ ปริ-
ฬาหา สเพฺพ สนฺตาปา สพฺพากุสลาภิสงฺขาร
จตฺตา วนฺตา มุตฺตา ปหีนา ปฏินิสฺสฏฺฐา ฯเปฯ อารมฺม
ณตฺตายเ ญาณํ ฯ

กตมํ อารมฺมณตฺตายเ ญาณํ ฯ อารมฺมณเตา กา-
เมหิ ขนฺธา กาเมหิ ธาตุโย กาเมหิ อายตนานิ กาเมหิ
อายุโย กาเมหิ สเพฺพ สงฺขารา กาเมหิ ขนฺธา ขนฺธ-
ปฏิพทฺธา ฉนฺทราคปฏิพทฺธา สมฺปยุตฺตกา ธมฺมา ฯเปฯ
สเพฺพ ปาปกา อกุสลา ธมฺมา ฯเปฯ อารมฺมณตฺตายเ ญาณํ ฯ

กตมํ อารมฺมณตฺตายเ ญาณํ ฯ อารมฺมณเตา
รูปา จกฺขุ มุขายตนสฺส วิมุขายตนสฺส ฯ โสตา

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ តើដូចម្តេច ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោល ហើយ នូវរាគៈ ។ ព្រះអរហន្ត លះបង់ ខ្ជាក់ចោល រួចស្រឡះ លះចោល រលាស់ចោលហើយ នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ តំលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្ត លោកនឹងធឹង ព្រោះជាអ្នកលះបង់ហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកឆ្ងាយហើយ តើដូចម្តេច ។ ព្រះអរហន្ត ឆ្ងាយកាមោយៈ ឆ្ងាយរោគៈ ឆ្ងាយទិដ្ឋិយៈ ឆ្ងាយអវិជ្ជាយៈ ឆ្ងាយ ឆ្ងាយផុត ឆ្ងាយស្រឡះ កន្ទងផុត កន្ទងហួស នូវផ្លូវគឺសង្សារទាំងអស់ ព្រះអរហន្តនោះ លោកមានកិរិយានៅ នៅស្រេចហើយ មានការប្រព្រឹត្តិ ប្រព្រឹត្តហើយ ។បេ។ កាលជាទៀត នៃព្រះអរហន្តនោះ មិនមានទេ ហេតុនោះ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកឆ្ងាយហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នកក្សួចហើយ តើដូចម្តេច ។ ចិត្តរបស់ព្រះអរហន្ត ក្សួច ក្សួចស្រឡះ ក្សួចផុតស្រឡះ ចាកពាគៈ ។

ជិតំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ មោរោ ជិតំ មុត្តំ វិមុត្តំ សុវិមុត្តំ ។ គោតោ ខុបតាហោ មក្ខោ បឌ្ឍាសោ ឥសប្បាយ មច្ចរិយោ មាយោយ សាឋេយ្យោ ជម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្ព-កិលេសេហិ សព្ពទុច្ចរិតេហិ សព្ពទរថេហិ សព្ពបរិឡាហេហិ សព្ពសន្តាបេហិ សព្ពាកុសលាភិសង្ខារេហិ ជិតំ មុត្តំ វិមុត្តំ សុវិមុត្តំ ឯវំ អរហា មុត្តោតិ តាទិ ។

កេនំ អរហា តាទិនេ្ទសោ តាទិ ។ អរហា សីលេ សតិ សីលវាតិ តាទិនេ្ទសោ តាទិ ។ សន្តាយ សតិ សន្តោតិ តាទិនេ្ទសោ តាទិ ។ វីរិយេ សតិ វីរិយវាតិ តាទិ-នេ្ទសោ តាទិ ។ សតិយោ សតិ សតិមាតិ តាទិនេ្ទសោ តាទិ ។ សមាធិស្មិំ សតិ សមាហិតោតិ តាទិនេ្ទសោ តាទិ ។ បញ្ញាយ សតិ បញ្ញវាតិ តាទិនេ្ទសោ តាទិ ។

ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកទោសៈ ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកមោហៈ ។ ចិត្តលោក រួច រួចស្រឡះ រួចផុតស្រឡះ ចាកកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងអស់ ទុច្ចរិតទាំងអស់ សេចក្តីក្រវល់ក្រវាយទាំងអស់ សេចក្តីក្តៅក្រហាយទាំងអស់ សេចក្តីអន្ទះអន្ទែងទាំងអស់ អកុសលាភិសង្ខារទាំងអស់ ព្រះអរហន្តលោកនឹងធឹង ព្រោះជាអ្នករួចហើយ យ៉ាងនេះ ។

ព្រះអរហន្តលោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះ តើដូចម្តេច ។ ព្រះអរហន្តលោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសីលមាន លោកជាអ្នកមានសីល ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសទ្ធាមាន លោកជាអ្នកមានសទ្ធា ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើវិរិយៈមាន លោកជាអ្នកមានវិរិយៈ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសតិមាន លោកជាអ្នកមានសតិ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើសមាធិមាន លោកជាអ្នកមានសមាធិ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើបញ្ញាមាន លោកជាអ្នកមានបញ្ញា ។

វិជ្ជាយ សតិ តេវិជ្ជោតិ តំនិទ្ទេសា តានិ ។ អភិ-
ញ្ញាយ សតិ ឆឡភិញ្ញោតិ តំនិទ្ទេសា តានិ ឯវំ
អរហា តំនិទ្ទេសា តានីតិ ចារិត្តំ តោ ន បញ្ញត្តិ តានិ ។
តេនាហ ភគវា

ន ភាវនាយ ន បុរេក្ខារេន
ឯម្ហាបិ តេសំ ន បដិច្ចតាសេ
ន ព្រាហ្មណោ សីលវតេន នេយ្យោ
ចារិត្តំ តោ ន បញ្ញត្តិ តានីតិ ។

បញ្ចមោ បរមដ្ឋកសុត្តនិទ្ទេសោ និដ្ឋិតោ ។

លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើវិជ្ជាមាន លោកជាអ្នកមានវិជ្ជាបីប្រការ ។ លោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះថា កាលបើអកិញ្ចាមាន លោកជាអ្នកមានអកិញ្ចាប្រាំមួយ ព្រះអរហន្តលោកនឹងធឹង ព្រោះការសំដែងចេញនូវហេតុនោះយ៉ាងនេះ ហេតុនោះ (ទ្រង់ត្រាស់ថា) លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទេ ។ ហេតុនោះ ព្រះមានព្រះភាគត្រាស់ថា

ព្រះអរហន្តខាងក្នុង មិនតែងតាំង មិនធ្វើឲ្យជាប្រធាន ដ្បិតធម៌ខាងក្នុង លោកមិនទទួលយកទេ ព្រាហ្មណ៍មិនមែនសីលវត្ត ជឹកនាំបានទេ លោកដល់ត្រើយហើយ ជាអ្នកនឹងធឹង មិនត្រឡប់មកវិញទៀយ ។

ចប់ បរមដ្ឋកសុត្តនិទ្ទេស ទី ៥ ។

(១៨១) អប្បំ វត ជីវិតំ នរំ

ឱរំ វស្សសតាបិ មិយ្យតិ

យោ ចេបិ អតិក្កូ ជីវិតំ

អថោ សោ ជរសាបិ មិយ្យតិ ។

(១៨២) អប្បំ វត ជីវិតំ នរន្តិ ជីវិតន្តិ អាយុ បិតំ យបនា យាបនា នរិយេនា វត្តនា ចាលនា ជីវិតំ ជីវិតុប្បដ្ឋំ ។ អបិច ទ្វីហិ ការណេហិ អប្បកំ ជីវិតំ ឆោកំ ជីវិតំ បិតិបវត្តតាយ ឯ អប្បកំ ជីវិតំ សរសបវត្តតាយ ឯ អប្បកំ ជីវិតំ ។

កថំ បិតិបវត្តតាយ អប្បកំ ជីវិតំ ។ អតីតេ ចិត្តក្ខណោ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ។ អនាគតេ ចិត្តក្ខណោ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ ។ បច្ចុប្បន្នេ ចិត្តក្ខណោ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ ។

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា

ឯកចិត្តសមាយុត្តា លហុសោ វត្តតិក្ខណោ

ជរាសុត្តនិទ្ទេស ទី ៦

(១៨១) (ព្រះមានព្រះភាគត្រាស់ថា) ជីវិតនេះតិចណាស់ រមែងស្ងាប់ខាងអាយុ អំពីមួយរយឆ្នាំ បើបុគ្គលណា រស់នៅកន្លងហួស (ពីមួយរយឆ្នាំ) ទៅ បុគ្គលនោះ ក៏ស្ងាប់ព្រោះដកពុំខាន ។

(១៨២) អធិប្បាយពាក្យថា ជីវិតនេះតិចណាស់ ត្រង់ពាក្យថា ជីវិត គឺអាយុ ការតាំងនៅ ការរស់នៅ ការញុំាងអត្តភាពឲ្យរស់នៅ ការដើរទៅ ការប្រព្រឹត្តិទៅ ការរក្សាជីវិត ជីវិតន្ទ្រិយ ។ មួយទៀត ជីវិតតិច ជីវិតស្តួចស្តើង ដោយហេតុពីរ គឺជីវិតតិច ព្រោះជាធម្មជាតតាំងនៅតិច១ ជីវិតតិច ព្រោះតិចរបស់ខ្លួនតិច១ ។

ជីវិតតិច ព្រោះធម្មជាតតាំងនៅតិច តើដូចម្តេច ។ សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន ធ៌មិនរស់នៅ ក្នុងអនាគតទេ ។ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនកំពុងរស់នៅ ក្នុងបច្ចុប្បន្ន មិនរស់នៅហើយ ក្នុងអតីតទេ ។ សត្វកំពុងរស់នៅក្នុងខណៈចិត្ត ជាបច្ចុប្បន្ន មិនបានរស់នៅហើយ ក្នុងអតីត នឹងមិនរស់នៅ ក្នុងអនាគតទេ ។

ជីវិត អត្តភាព សុខទុក្ខ ក៏ដូចគ្នាអស់ ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈ ប្រព្រឹត្តទៅរហ័ស

ปญฺจสีลานิ สมาทิยิตฺวา กายสฺส เภทา ปรมฺมรณา ยเ ปรา

น ภเวยฺย เตปิ ตาวเทว ทิฏฺเ ธมฺเ สมาหิตา[๑]

เย อิมสฺมา มนุสฺสา ปรมฺมรณา ปน ๕๐

สเตฺวสุ สนิกาเย ขตฺตา ตตา อปฺปฏิสนฺธิกา

อนนฺตกา จ เย ภกฺขา เย จ ภกฺขา อนาคตา

ตนนฺตเร อิมสฺมิงฺ เวสฺมึ นตฺถิ ลกฺขณา

อนิมิตฺตเน น ตาเตา ปจฺจุปฺปนฺเน น ตีสุปิ

จิตฺตภงฺคมตา เลาเกา ปญฺญตฺติ ปรมตฺถิยา

ยถา อิตฺถา มหาภูเต น เตเน ปริณามิตา

อิจฺเจวมาท[๒] ภูเตหิ สทฺธายตนปฺปจฺจยา

อนิจฺจตา ตตา ภกฺขา ปุเญฺญ นตฺถิ อนาคเต

อิมสฺมาเยว ฐานมฺหิ อารเภ สาสนูปมา

---

๑ ม. สมาหิตา ฯ ๒ ม. อิจฺเจวมาทิ ฯ

ពួកទេវតាណា បិតនៅអស់ ៨៤ ពាន់តប្បៈ ទេវតាទាំងនោះ មិនមែនប្រកបដោយចិត្ត ๒ ហើយរស់នៅទេ ខន្ធទាំងឡាយណា របស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ដូចគ្នា ទៅបដិសន្ធិទៀតមិនបាន ខន្ធទាំងឡាយណា ដែលកន្ទងទៅជាលំដាប់ បែកធ្លាយហើយផង ខន្ធទាំងឡាយណា ជាអនាគត នឹងបែកធ្លាយផង សេចក្តីផ្សេងគ្នានៃខន្ធទាំងឡាយ ជាបច្ចុប្បន្ន ដែលរលត់ហើយ ក្នុងចន្លោះ នៃខន្ធទាំងពីរនោះ រមែងមិនមានក្នុងលក្ខណៈ សត្វលោក ដែលកើតហើយដោយអនាគតក្ខន្ធ ដែលមិនទាន់កើត មិនឈ្មោះថា រស់នៅហើយទាំងមិនឈ្មោះថា កំពុងរស់នៅក្នុងខន្ធជាបច្ចុប្បន្នទេ សត្វលោកស្លាប់ ដោយការបែកធ្លាយនៃចិត្ត (នេះជា) បញ្ញត្តិនៃបរមត្ថ ការប្រែប្រួលទៅដោយឆន្ទៈ ដូចជាទឹកដោះ រមែងប្រព្រឹត្តទៅជូរជាដើម វេទនាទាំងឡាយ មានសភាពយ៉ាងនេះជាបច្ច័យ មានវារៈមិនដាច់ តែងប្រព្រឹត្តទៅ ខន្ធទាំងឡាយ ដែលបែកធ្លាយហើយ ក៏មិនដល់នូវការតាំងលំនៅ គំនរនៃខន្ធ ក្នុងអនាគត ក៏មិនមាន ខន្ធទាំងឡាយ ដែលកើតឡើងហើយ រមែងបិតនៅ ដូចគ្រាប់ស្វៃ ដែលបិតនៅលើចុងដែកស្រួច

ជំពូតារេញ្ច ឆម្ចាំ ភជ្ជោ នេសំ បុរេក្ខ្វតោ
បលោភេឆម្ចា តិដ្ឋន្តំ ទោភណោមា អមិស្សិតា
អនស្សនតោ អាយន្តំ ភជ្ជា តច្ចន្តំនស្សរំ
វិដ្ឋប្បាទោវ អាភាសេ ខុប្បដ្ឋន្តំ វយន្តំ ចាតំ ។
ឃាំ បិតិបវត្តតាយ អប្បកំ ជីវិតំ ។

ភេថំ សរសបវត្តតាយ អប្បកំ ជីវិតំ ។ អស្សា-
សុបដិពទ្ធំ ជីវិតំ បស្សាសុបដិពទ្ធំ ជីវិតំ អស្សាស-
ប្បស្សាសុបដិពទ្ធំ ជីវិតំ មហាភូតុបដិពទ្ធំ ជីវិតំ ឧស្ម-
បដិពទ្ធំ ជីវិតំ ភេវង្គឆ្លាភហារុបដិពទ្ធំ ជីវិតំ វិញ្ញាណុ-
បដិពទ្ធំ ជីវិតំ ។ មូលមូរ្ហ ឥមេសំ ទុព្ភលំ ។ បុព្ព-
ហេភូបិ ឥមេសំ ទុព្ភលា ។ យេបិ បច្ចយា តេបិ
ទុព្ភលា ។ យេបិ បភវិតោ តេបិ ទុព្ភលា ។ សហភូបិ
ឥមេសំ ទុព្ភលា ។ សម្បយោតាបិ ឥមេសំ ទុព្ភ-
លា ។ សមាជាបិ ឥមេសំ ទុព្ភលា ។

กาลเป็นขันธ์ดับไป เกิดขึ้นแล้ว ความแปรปรวนแห่งขันธ์นั้น ชื่อว่าปวัตตะในขันธ์ทั้งหลาย ส่วนอาการที่ขันธ์ดับไป (ขันธ์) ชื่อว่าปวัตตะหามิได้ ไม่ประกอบประกอบด้วยขันธ์ด้วย ไม่มีความคิดเห็นว่าเป็นขันธ์ ชื่อว่าแปรปรวนแล้ว ไม่มีความคิดเห็นว่าเป็นขันธ์ ชื่อว่าแปรปรวนแล้วด้วย ชื่อว่าเกิดขึ้นด้วย ชื่อว่าวินาศด้วย ดุจดังเรือนยอดในอากาศ ฯ ชื่อว่าติด เพราะความปวัตตะติด อย่างนี้ ฯ

ชื่อว่าติด เพราะติดประกอบด้วยขันธ์ติด เป็นอย่างไร ฯ ชื่อว่าติดด้วยฉันทราคะว่าเข้าไปยึดถือ ชื่อว่าติดด้วยฉันทราคะว่าออกไปยึดถือ ชื่อว่าติดด้วยฉันทราคะว่าเข้าไปยึดถือและออกไปยึดถือ ชื่อว่าติดด้วยมหาภูตรูป ชื่อว่าติดด้วยธาตุ ชื่อว่าติดด้วยอาหาร ชื่อว่าติดด้วยวิญญาณ ฯ บุคคลผู้ประกอบด้วยธรรมชาตินี้ มีความยึดถือ ฯ เหตุแห่งความยึดถือของธรรมชาตินี้ มีความยึดถือ ฯ ความยึดถือในธรรมชาตินี้ มีความยึดถือ ฯ ความยึดถือในธรรมชาติเป็นปัจจัย ธรรมชาตินั้น มีความยึดถือ ฯ ความยึดถือในธรรมชาติ ที่ประกอบ ธรรมชาตินั้น มีความยึดถือ ฯ ความยึดถือในธรรมชาติที่เกิดขึ้น ด้วยอำนาจธรรมชาตินี้ มีความยึดถือ ฯ ความยึดถือในธรรมชาติที่ประกอบด้วยกัน ด้วยอำนาจธรรมชาตินี้ มีความยึดถือ ฯ ธรรมชาติที่เกิดขึ้น ด้วยอำนาจกันและกันด้วยอำนาจธรรมชาตินี้ มีความยึดถือ ฯ

ยาปิ ปเรสญฺจ สาปิ ฆาตนา ฯ อญฺญมญฺญ
ฆาตนา ฯเป ฯ อญฺญมญฺญ อนวฏฺฐิตา ฯเป ฯ
อญฺญมญฺญ ปริภวนฺติ ฯเป ฯ อญฺญมญฺญสฺส หิ ฉฏฺ
ฐายิตา ฯ ฉ ตาปิ ปเรสุ อญฺญมญฺญเมว ฯ เยปิ
ฉฏฺฐกา สา ฉ วิชฺชติ ฯ ฉ จ ภิกฺขเว ตาปิ
หายติ ฯ กณฺฏฺฐา[1] จ ฯเป สพฺพสา ฯ
ปุริเมหิ ปกาวิตา ฯเป ฯ เยปิ ปกาวิตา เต ปุเร
มตา ฯ ปุริมาปิ จ ปจฺฉิมาปิ จ อญฺญมญฺญ ฉ ภกฺขาติ
อฏฺฐสีสกา ฯ ฆา สาสปริฏฺฐาย อปฺปกา ชีวิตา ฯ

อปิจ จาตุมฺหาภิกานี ฉกฺขณี ชีวิตา ขุทฺ-
ทกาย มนุสฺสานี อปฺปกา ชีวิตา ปริตฺตกา ชีวิตา ปโกกา
ชีวิตา ฯณิกา ชีวิตา ลหุกา ชีวิตา มุตฺตา ชีวิตา อ-
ฉนฺทนิยา ชีวิตา ฉ จิรฏฺฐิติกา ชีวิตา ฯ ตาวตฺตึสานี
ฉกฺขณี ฯ ยามานี ฉกฺขณี ฯ ตุสิตานี ฉกฺขณี ฯ
นิมฺมานรตีนี ฉกฺขณี ฯ ปรนิมฺมิตวสวตฺตีนี ฉกฺขณี ฯ
พฺรหฺมกายิกานี ฉกฺขณี ชีวิตา ขุทฺทกาย มนุสฺสานี
อปฺปกา ชีวิตา ปริตฺตกา ชีวิตา ปโกกา ชีวิตา ฯณิกา

---

๑ ม. คนฺถา ฯ

ធម្មជាតិណាជាគ្រឿងប្រកប ធម្មជាតិនោះ ក៏មានកម្លាំងឋិយ ។ ធម៌ទាំងនេះ មានកម្លាំងឋិយជាន់ចូដល់គ្នានឹងគ្នា ។ ធម៌ទាំងនេះ មិនខុនវេគ្គានឹងគ្នា ។ ធម៌ទាំងនេះ ញ៉ាំងគ្នានឹងគ្នាឲ្យភ្ជាប់ចុះ ។ ព្រោះមិនបានជាទំពឹងដល់គ្នានឹងគ្នា ។ មួយទៀត ធម៌ទាំងនេះ មិនតំកល់ខុកន្លូគ្នានឹងគ្នា ។ សូម្បីធម៌ណា ជាអ្នកបង្កើត ធម៌នោះ ក៏មិនមាន ។ ធម៌ណាមួយ មិនមែនវិនាស ដោយធម៌ណាមួយទេ ។ ព្រោះថា ធម៌ទាំងនេះ បែកធ្លាយទៅដោយប្រការទាំងពួង ។ ធម៌ទាំងនេះ កើតហើយ ព្រោះហេតុនឹងបច្ច័យអំពីមុន ។ ហេតុនឹងបច្ច័យទាំងឡាយណា ដែលឲ្យកើតមុន ហេតុនឹងបច្ច័យទាំងនោះ ក៏ស្ងាប់មុនទៅហើយ ។ ធម៌ទាំងឡាយខាងដើមនឹងខាងចុង មិនបានឃើញគ្នានឹងគ្នា ក្នុងកាលណាមួយឡើយ ។ ជីវិតតិច ព្រោះតិចរបស់ខ្លួនតិច យ៉ាងនេះ ។

មួយទៀត ពួកមនុស្ស មានជីវិតតិច ជីវិតសួចស្តើង ជីវិតខ្លី ជីវិតមានក្នុងមួយខណៈ ជីវិតរហ័ស ជីវិតធាប់ ជីវិតមិនមាំមួន ជីវិតមិនបឋមទៅយូរ បើប្រៀបផ្ទឹមនឹងជីវិត របស់ពួកទេវតាជាន់ចាតុម្មហារាជិកា ។ របស់ពួកទេវតាជាន់តាវត្តិង្ស ។ របស់ទេវតាជាន់យាមៈ ។ របស់ទេវតាជាន់តុសិត ។ របស់ទេវតាជាន់និម្មានរតី ។ របស់ទេវតា ជាន់បរនិម្មិតវសវត្តី ។ ពួកមនុស្ស មានជីវិតតិច ជីវិតសួចស្តើង ជីវិតថោកថយ ជីវិតមានក្នុងមួយខណៈ

ជីវិតំ លេហុកាំ ជីវិតំ ឥត្តរំ ជីវិតំ អនេឆជយំ ជីវិតំ
ន ចិរដ្ឋិតិកាំ ជីវិតំ ។ ភូតំ ខោតំ កតវតា អប្បមិទំ
កិក្ខវេ មនុស្សានំ អាយុ តមនីយោ សម្បរាយោ
មច្ចាយ ជោដ្ឋំ ភត្តំ កុសលំ ចរិតព្ពំ ព្រហ្មចរិយំ
ឧត្តំ ជាតស្ស អមរណំ យោ កិក្ខវេ ចិរំ ជីវិតំ សោ
វស្សសតំ អប្បំ វា កិរេយ្យា

អប្បមាយុ មនុស្សានំ ហិរេឞ្ញេយ្យ ំ សុភោវិសោ
ចរេយ្យាដិត្តសីសោវ ឧត្តំ មច្ចុស្ស ជាតមោ
អច្ចយន្តិ អហោរត្តា ជីវិតំ ឧបរុជ្ឈតិ
អាយុ ខីយតិ មច្ចានំ កុន្នទីនំវ ឧទកន្តិ ។

អប្បំ វត ជីវិតំ ឥទំ ។

(១៨៣) ឯវំ វស្សសតាបិ មិយ្យតីតិ កលលកាលេបិ ចវតិ មរតិ អណ្ឌជាយតិ វិប្បលុជ្ជតិ ។ អណ្ឌកោសេបិ ចវតិ មរតិ អណ្ឌជាយតិ វិប្បលុជ្ជតិ ។ ជេសិកាលេបិ ចវតិ មរតិ អណ្ឌជាយតិ វិប្បលុជ្ជតិ ។

ជីវិតរហ័ស ជីវិតធាប់ ជីវិតមិនមាំមួន ជីវិតមិនបឋមទៅយូរ បើប្រៀបផ្ទឹមនឹងជីវិតរបស់ទេវតាព្រហ្មកាយិកៈ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះតិច បរលោកពួកសត្វត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយៈ (ព្រោះថា) សត្វដែលកើតហើយ មិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់ទៅអស់កាលយូរ បុគ្គលនោះ គប្បីរស់នៅ ១០០ ឆ្នាំ តិចពីមួយរយឆ្នាំ ឬច្រើនជាង ១០០ ឆ្នាំ ។

> អាយុរបស់ពួកមនុស្ស តិច បុរសល្អគប្បីធ្វើយ៉ាងណាយ នឹងអាយុនោះ គប្បីប្រព្រឹត្តដូចជាបុគ្គល ដែលភ្លើងឆេះក្បាលដំណើរមិនមកនៃមច្ចុ មិនមានទេ ថ្ងៃនឹងយប់តែងកន្ត្រងទៅ ជីវិតក៏ស្រកស្រុតទៅដែរ អាយុរបស់ពួកសត្វ រមែងអស់ទៅដូចជាទឹកនៃស្ទឹងតូចទាំងឡាយ ។

ហេតុនេះ (ទ្រង់ត្រាស់ថា) ជីវិតនេះ តិចណាស់ ។

(១៨៣) ពាក្យថា សត្វរមែងស្លាប់ខាងអាយុអំពីមួយរយឆ្នាំ អធិប្បាយថា សត្វរមែងច្យុត ស្លាប់ ឃាត់បង់ វិនាស ក្នុងកាលជាកលលៈ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ ឃាត់បង់ វិនាស ក្នុងកាលជាអម្ពុទៈ ក៏មាន ។ សត្វរមែងច្យុត ស្លាប់ ឃាត់បង់ វិនាស ក្នុងកាល ជាបេសិ ក៏មាន ។

ឃនកោលេបិ ចវតិ មរតិ អន្តរាយតិ វិប្បលុជ្ជតិ ។
បញ្ចសាខកោលេបិ ចវតិ មរតិ អន្តរាយតិ វិប្បលុ-
ជ្ជតិ ។ ជាតិមត្តោបិ ចវតិ មរតិ អន្តរាយតិ
វិប្បលុជ្ជតិ ។ បស្សតិយរេបិ ចវតិ មរតិ អន្តរាយតិ
វិប្បលុជ្ជតិ ។ អង្គុមាសិកោបិ ចវតិ មរតិ អន្តរា-
យតិ វិប្បលុជ្ជតិ ។ មាសិកោបិ ចវតិ មរតិ អន្ត-
រាយតិ វិប្បលុជ្ជតិ ។ ទ្វិមាសិកោបិ តិមាសិកោបិ
ចតុម្មាសិកោបិ បញ្ចមាសិកោបិ ចវតិ មរតិ អន្ត-
រាយតិ វិប្បលុជ្ជតិ ។ ឆមាសិកោបិ សត្តមាសិកោបិ
អដ្ឋមាសិកោបិ នវមាសិកោបិ ទសមាសិកោបិ
សំវច្ឆរិកោបិ ចវតិ មរតិ អន្តរាយតិ វិប្បលុជ្ជតិ ។
ទ្វិវស្សិកោបិ តិវស្សិកោបិ ចតុវស្សិកោបិ បញ្ច-
វស្សិកោបិ ឆវស្សិកោបិ សត្តវស្សិកោបិ អដ្ឋវស្សិ-
កោបិ នវវស្សិកោបិ ទសវស្សិកោបិ វីសតិវស្សិ-
កោបិ តឹសវស្សិកោបិ ចត្តាឡីសវស្សិកោបិ បញ្ញា-
សវស្សិកោបិ សដ្ឋិវស្សិកោបិ សត្តតិវស្សិកោបិ
អសីតិវស្សិកោបិ នវុតិវស្សិកោបិ ចវតិ មរតិ អន្ត-
រាយតិ វិប្បលុជ្ជតីតិ ឯវំ វស្សសតាបិ មិយ្យតិ ។

សត្វមែងប្រុស ស្វាប់ ចាត់បង់ វិនាស ក្នុងកាល ដាយនៈ ក៏មាន ។ សត្វមែងប្រុស ស្វាប់ ចាត់បង់ វិនាស ក្នុងកាល ដាបញ្ចសាខា ក៏មាន ។ សត្វគ្រាន់តែមានកំណើត ប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វមែងប្រុស ស្វាប់ ចាត់បង់ វិនាស ក្នុងផ្ទះជាទីប្រសូតិ ក៏មាន ។ សត្វកើតបានកន្លះខែប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ១ ខែ ប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ខែខ្ទះ បាន ៣ ខែខ្ទះ បាន ៤ ខែខ្ទះ បាន ៥ ខែខ្ទះ ប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ៦ ខែខ្ទះ ៧ ខែខ្ទះ ៨ ខែខ្ទះ ៩ ខែខ្ទះ ១០ ខែខ្ទះ ១ ឆ្នាំខ្ទះ ប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ។ សត្វកើតបាន ២ ឆ្នាំខ្ទះ ៣ ឆ្នាំខ្ទះ ៤ ឆ្នាំខ្ទះ ៥ ឆ្នាំខ្ទះ ៦ ឆ្នាំខ្ទះ ៧ ឆ្នាំខ្ទះ ៨ ឆ្នាំខ្ទះ ៩ ឆ្នាំខ្ទះ ១០ ឆ្នាំខ្ទះ ២០ ឆ្នាំខ្ទះ ៣០ ឆ្នាំខ្ទះ ៤០ ឆ្នាំខ្ទះ ៥០ ឆ្នាំខ្ទះ ៦០ ឆ្នាំខ្ទះ ៧០ ឆ្នាំខ្ទះ ៨០ ឆ្នាំខ្ទះ ៩០ ឆ្នាំខ្ទះ ប្រុស ស្វាប់ ចាត់បង់ វិនាសទៅវិញ ក៏មាន ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលមែងស្វាប់ខាងអាយុ អំពីមួយរយឆ្នាំ ។

(๑๘๔) យោ ខេបិ អតិច្ច ជីវតីតំ យោ វស្ស-
សតំ អតិក្កមិត្វា ជីវតិ សោ ឯកំ វ វស្សំ ជីវតិ
ទ្វេ វ វស្សានិ ជីវតិ តីណិ វ វស្សានិ ជីវតិ
ចត្តារិ វ វស្សានិ ជីវតិ បញ្ច វ វស្សានិ ជីវតិ
ឆ វ វស្សានិ ជីវតិ សត្ត វ វស្សានិ ជីវតិ
អដ្ឋ វ វស្សានិ ជីវតិ នវ វ វស្សានិ ជីវតិ
ទស វ វស្សានិ ជីវតិ ចត្តាឡីសំ វ វស្សានិ
ជីវតីតិ យោ ខេបិ អតិច្ច ជីវតិ ។

(๑๘๕) អថខោ សោ ជរសាបិ មិយ្យតីតិ យថា
ដិណ្ណោ ភោតិ ភុញ្ជា មហល្លកោ អទ្ធគតោ វយោ-
អនុប្បត្តោ ខណ្ឌទន្តោ បលិតកេសោ វិលូនំ ខលិត-
សិរោ វលីនំ តិលកាហតគត្តោ វង្កោ កត្តោ ទណ្ឌប-
ភយោ សោ ជរាយបិ ចវតិ មរតិ អន្តរធាយតិ
វិបរិណ្ឌតិ ។

ឧត្តិ មរណាម្ហា មោក្ខោ
ជលានមិវ បក្កានំ ឆាតោ បតនតោ ភយំ
ឯវំ ជាតានមច្ចានំ និច្ចំ មរណតោ ភយំ

(๑๘๔) ពាក្យថា បើបុគ្គលណា រស់នៅកន្លងហួសទៅ គឺ បុគ្គលណា រស់នៅកន្លងមួយរយឆ្នាំ បុគ្គលនោះ រស់នៅអស់ ១ ឆ្នាំក្តី រស់នៅអស់ ២ ឆ្នាំក្តី រស់នៅអស់ ៣ ឆ្នាំក្តី រស់នៅអស់ ៤ ឆ្នាំក្តី រស់នៅអស់ ៥ ឆ្នាំក្តី រស់នៅអស់ ១០ ឆ្នាំក្តី រស់នៅអស់ ២០ ឆ្នាំក្តី រស់នៅអស់ ៣០ ឆ្នាំក្តី រស់នៅអស់ ៤០ ឆ្នាំក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) បើបុគ្គលណា រស់នៅកន្លងហួសទៅ ។

(๑๘๕) ពាក្យថា បុគ្គលនោះ គង់ស្លាប់ ព្រោះដកពុំខាន អធិប្បាយថា កាលណា បុគ្គលចាស់ ចំរើនដោយវ័យ មានអាយុប្រើនកន្លងកាល ជ្រុលចូលក្នុងបច្ឆិមវ័យ មានធ្មេញបាក់ សក់ស្កូវ ក្បាលឆកក្បាលថ្លែក សែ្បកជ្រួញជ្រីវ មានខ្លួនវន្ទុះដោយប្រជ្រុយ ខ្លួនកោងកូត់ កាន់ឈើច្រត់ បុគ្គលនោះ គង់ប្តូត ស្លាប់ ឃាត់បង់ វិនាស ព្រោះជរា ។

ការរួចចាកមរណៈ មិនមានទេ សត្វទាំងពួយ ដែលកើតហើយ តែងមានភ័យអំពីមរណៈជានិច្ច ដូចជាផ្លែឈើទុំទាំងពួយ តែងមានភ័យអំពីការជ្រុះចុះ ក្នុងវេលាព្រឹក

យថាបិ កុម្ភការស្ស ភតា មត្តិកភាជនា
សព្ពេ ភេទមវយ្ហន្តា[1] ឯវំ មច្ចាន ជីវិតំ
ឧមារ ច មហាឡា ច យេ ពាលា យេ ច បណ្ឌិតា
សព្ពេ មច្ចុវសំ យន្តិ សព្ពេ មច្ចុបរាយនា
តេសំ មច្ចុបរេតានំ តត្ថ តំ បរលោកតោ
ន បិតា តាយតេ បុត្តំ ញាតី វា បន ញាតកេ
បេក្ខតញ្ញេវ ញាតីនំ បស្ស លាលប្បតំ បុថូ
ឯកមេកោវ មច្ចានំ គោវជ្ឈោ វិយ និយ្យតិ
ឯវំ អព្ភាហតោ លោកោ មច្ចុនា ច ជរាយ ចាតិ ។

អថខោ សោ ជរសាបិ មិយ្យតិ ។ តេនាហ ភគវា

អប្បំ វត ជីវិតំ ឥទំ
ឱរំ វស្សសតាបិ មិយ្យតិ
យោ ចេបិ អតិច្ចំ ជីវតិ
អថខោ សោ ជរសាបិ មិយ្យតីតិ ។

---

១ ម. ភេទនបរិយន្តា ។

ភាវនាដ៏ ដែលកុប្បកាវត្តៀហើយ ទាំងអស់ មានការបែក
ធ្លាយជាទីបំផុត យ៉ាងណា ជីវិត របស់សត្វទាំងឡាយ
ក៏យ៉ាងនោះដែរ ពួកជនណា ទាំងក្មេង ទាំងចាស់ ទាំង
ពាល ទាំងបណ្ឌិត ពួកជនទាំងអស់នោះ រមែងលុះអំ-
ណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅជាមុខ
កាលពួកជនទាំងនោះ ដែលមច្ចុគ្របសង្កត់ ទៅកាន់បរ-
លោក បិតាពឹងបុត្តមិនបាន ឬថាពួកញាតិពឹងពួកញាតិក៏
មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសំឡឹងមើល
កំពុងយំវៀរភាប់ច្រើន សត្វលោក ដែលត្រូវមច្ចុនឹងជក
បំផ្លាញហើយ ដូចជាបណ្តាសត្វទាំងឡាយ គោមួយ ។
ដែលគេត្រូវនាំទៅសម្លាប់ ។

ហេតុនោះ (ព្រះធម៌ត្រាស់ថា) បុគ្គលនោះគង់ស្លាប់ ព្រោះជរាពុំខាន ។
ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ជីវិតនេះ តិចណាស់ រមែងស្លាប់ខាងអាយុ អំពីមួយរយឆ្នាំ
ប៉ែបុគ្គលណា រស់នៅកន្លងហួស (ពីមួយរយឆ្នាំ) ទៅ
បុគ្គលនោះ គង់ស្លាប់ ព្រោះជរាពុំខាន ។

(๑๘๖) សោចន្តិ ជនា មមាយិតេ

ន ហិ សន្តិ និច្ចា បរិគ្គហា

វិនាភាវសន្តមេវិទំ

ឥតិ ទិស្វា នាគារមាវសេ ។

(๑๘๗) សោចន្តិ ជនា មមាយិតេតិ ជនាតិ ខត្តិយោ ច ព្រាហ្មណោ ច វេស្សោ ច សុទ្ទោ ច គហដ្ឋោ ច បព្ពជិតោ ច ទេវោ ច មនុស្សោ ច ។ មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ អយំ តណ្ហាមមត្តំ ។ បេ ។ អយំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុអភេទេសញ្ញិនោបិ សោចន្តិ អច្ឆិជ្ជភេទេបិ សោចន្តិ អច្ឆេជ្ជេបិ សោចន្តិ មមាយិតវត្ថុវិបរិណាមសញ្ញិនោបិ សោចន្តិ វិបរិណាមភេទេបិ សោចន្តិ វិបរិណាតេបិ សោចន្តិ កិលមន្តិ បរិទេវន្តិ ទុរត្តាឡឺ កន្ទន្តិ សម្មោហំ អាបជ្ជន្តីតិ សោចន្តិ ជនា មមាយិតេ ។

(๑๘๖) ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ការហួងហែងនាំឲ្យ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះ មានសភាពប្រែប្រួលជាប្រាកដ បុគ្គលកាលឃើញដូច្នេះ ហើយ មិនគួរនៅក្នុងគ្រប់គ្រងផ្ទះទៀតឡើយ ។

(๑๘๗) អធិប្បាយពាក្យថា ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ត្រង់ពាក្យថា ពួកជន បានដល់ ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គហស្ថ បព្វជិត ទេវតា មនុស្ស ។ ពាក្យថា ការហួងហែង បានដល់ការហួងហែង ๒ គឺការហួងហែងគឺតណ្ហា ๑ ការហួងហែងគឺទិដ្ឋិ ๑ ។ បេ ។ នេះការហួងហែងគឺតណ្ហា ។ បេ ។ នេះការហួងហែងគឺទិដ្ឋិ ។ ពួកជនជាអ្នកមានសេចក្តីរង្គើស ដោយការដណ្តើមយកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលគេកំពុងដណ្តើមយក ក៏មាន សោកស្តាយចំពោះវត្ថុដែលគេដណ្តើមយកហើយ ក៏មាន ពួកជន មានសេចក្តីរង្គើសដោយការប្រែប្រួលចាកវត្ថុដែលហួងហែង រមែងសោកស្តាយ ក៏មាន សោកស្តាយចំពោះវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្តាយចំពោះវត្ថុដែលប្រែប្រួលហើយ ក៏មាន រមែងលំបាក ខ្សឹកខ្សួល គក់ទ្រូង ដល់នូវការវង្វេង ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជន រមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ។

[๑๘๘] ឧ ឥតិ សង្ខំ ឯត្ថោ បរិគ្គហោតិ បរិគ្គហោតិ
ទ្វេ បរិគ្គហោ តណ្ហាបរិគ្គហោ ច ទិដ្ឋិបរិគ្គហោ ច
។ បេ ។ អយំ តណ្ហាបរិគ្គហោ ។ បេ ។ អយំ ទិដ្ឋិប-
រិគ្គហោ ។ តណ្ហាបរិគ្គហោ អនិច្ចោ សង្ខតោ បដិច្ចស-
មុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធ-
ធម្មោ វិបរិណាមធម្មោ ។ ទិដ្ឋិបរិគ្គហោ អនិច្ចោ សង្ខ-
តោ បដិច្ចសមុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ
និរោធធម្មោ វិបរិណាមធម្មោ ។ វុត្តំ ហេតំ ភគវតា
បស្ស ភោ តុម្ហេ ភិក្ខវេ តំ បរិគ្គហំ យ្វាយំ បរិគ្គ-
ហោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ
សស្សតិសមំ តថេវ ឋស្សតីតិ ។ នោ ហេតំ ភន្តេ ។
សាធុ ភិក្ខវេ អមាមកា ខោ ឋំ ភិក្ខវេ បរិគ្គហំ ឧ
សមនុបស្សថ យ្វាយំ បរិគ្គហោ និច្ចោ ធុវោ សស្ស-
តោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតីតិ ។

(๑๘๘) អធិប្បាយពាក្យថា ការហួងហែងពាំងឡាយ ពុំមែនដាក់ទៀងទាត់ទេ ត្រង់ពាក្យថា ការហួងហែង ចាន់ដល់ការហួងហែង ๒ គឺការហួងហែងតិណ្ហា ๑ ការហួងហែងទិដ្ឋិ ๑ ។ បេ ។ នេះការហួងហែងតិណ្ហា ។ បេ ។ នេះការហួងហែងទិដ្ឋិ ។ ការហួងហែងតិណ្ហាជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ ការហួងហែងទិដ្ឋិ ជាសភាពមិនទៀង ដែលបច្ច័យតាក់តែង កើតឡើង ព្រោះអាស្រ័យ (បច្ច័យ) មានការអស់ទៅជាធម្មតា វិនាសទៅជាធម្មតា ប្រាសទៅជាធម្មតា រលត់ទៅជាធម្មតា ប្រែប្រួលទៅជាធម្មតា ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុពាំងឡាយ អ្នកពាំងឡាយ ចាប់យើញការហួងហែង ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅ ស្មើដោយសស្សតិវត្ត ដូច្នោះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរនុ៎ះយើងខ្ញុំមិនចាប់យើញទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុពាំងឡាយ ប្រពៃហើយ ម្នាលភិក្ខុពាំងឡាយ តថាគត ក៏ពិចារណាមិនយើញនូវការហួងហែងនុ៎ះ ដែលជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួលជាធម្មតា ឋិតនៅស្មើដោយសស្សតិវត្ត ដូច្នោះដែរ ។

បរិក្ខារោ ដំឡូ ឆុកា សស្សតា អវិបរិណាមធម្មា ឆន្នំ ន សន្តិ ន សំវិជ្ជន្តិ ឧបលព្ភន្តីតិ ន ហិ សន្តំ ដំឡូ បរិក្ខារោ ។

(๑๘๙) រោគាសន្តមេវិទន្តិ ឯតាគារេ រោគាគារេ អញ្ញាគារេ សន្តេ សំវិជ្ជមានេ[๑] ឧបលព្ភិយមានេ ។ រុក្ខំ ហោតំ ភគវតា អលំ អានន្ទ មា សោចិ មា បរិទេវិ ឧទុ ឋិតំ អានន្ទ មយា បដិកច្ចេវ[๒] អក្ខាតំ សព្ពេហេវ បិយេហិ មនាបេហិ ឯតាគារេ រោគាគារេ អញ្ញាគារេ តំ ភុត្តេត្ថ អានន្ទ លព្ភា យន្តំ ឯតំ ភូតំ សង្ខតំ បលោកធម្មំ តំ វត មា បលុជ្ជីតិ ឯតំ ឋានំ វិជ្ជតីតិ ។ បុរិមានំ បុរិមានំ ខន្ធានំ ឯតាគារេ អាយតនានំ បរិបរិណាមញ្ញថាភាវា បច្ចិមា បច្ចិមា ខន្ធា ច ឯតាគារេ ច អាយតនានំ ច បវត្តន្តីតិ រោគាសន្តមេវិទំ ។

---

๑ ម. សំវិជ្ជមានេ អត្ថិ ។ ๒ បដិគច្ចេវាតិបិ ឯកច្ចេ ។

ការហួងហែងទាំងឡាយ ជាសភាពទៀង មាំមួន ឋិតថេរ មិនប្រែប្រួល ជាធម្មតា ឥតមាន មិនដែលមាន មិនមានប្រាកដ មិនកើតមានទេ ហេតុនោះ (ទ្រង់ត្រាស់ថា) ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ ។

(១៨៩) ពាក្យថា វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត គឺ ភាវៈផ្សេង ។ ភាវៈព្រាត់ប្រាស ភាវៈទៅជាយ៉ាងដទៃ កាលមាន កាលកានព្រម កាលកើតមាន ។ សមដូចពាក្យនេះ ដែលព្រះមានបុណ្យ ត្រាស់ហើយថា ម្នាលអានន្ទ មិនគួរទេ អ្នកកុំសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ ក្រែងតថាគតបានពោលហើយ ក្នុងកាលមុន នូវពាក្យនេះថា ភាវៈផ្សេង ។ ភាវៈព្រាត់ប្រាស ភាវៈជាយ៉ាងដទៃ ចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ពេញចិត្តដូច្នេះឬ ម្នាលអានន្ទ បុគ្គលគប្បីបាននូវហេតុនោះ ក្នុងសត្វនិងសង្ខារទាំងនោះ អំពីណាថា វត្ថុណាកើតហើយ ប្រាកដហើយ តាក់តែងហើយ មានកិរិយាវិនាសជាធម្មតា ចុះវត្ថុនោះ កុំវិនាសឡើយ ដំណើរនោះមិនសមហេតុទេ ។ ព្រោះសេចក្តីប្រែប្រួលជាយ៉ាងដទៃ របស់ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលមុន ។ ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលខាងក្រោយ ។ កំរែមធ្វើប្រព្រឹត្តទៅ (ដូចគ្នា) ហេតុនោះ (ទ្រង់ត្រាស់ថា) វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត ។

(๑๙๐) ส๎วาหิ นิสฺสา ชาคารมาวสเตติ ส๎วาหีติ ปทสนฺธิ ปทสํสคฺโค ปทปารปูริ[๑] อกฺขรสมวายโย ฯเปฯ สิลิฏฺฐตา ปทธาตุปทฺธกเมตํ ส๎วาหีติ ฯ ส๎วาหิ นิสฺสา ปสฺสิตฺวา สุตฺวา ตีรยิตฺวา วิภาวยิตฺวา วิภูตํ กตฺวา มมตฺตเสฺสตํ ส๎วาหิ นิสฺสา ฯ ชาคารมาวสเตติ สพฺเพ ยกฺขา สมลิเภาคํ นิกฺขิตฺตา ปุตฺตา ธารมลิเภาคํ นิกฺขิตฺตา ญาติมลิเภาคํ นิกฺขิตฺตา มิตฺตามจฺจมลิเภาคํ นิกฺขิตฺตา สนฺถิมลิเภาคํ นิกฺขิตฺตา เกสมสฺสุ ฉิทฺทาเปตฺวา กาสาวานิ วตฺถานิ อจฺฉาเปตฺวา อคารสฺมา อนคาริยํ ปพฺพชิตฺวา อากิญฺจญฺญาตฺวา อุปคนฺตฺวา ฯเปฯ จเยยฺย วิมาเยยฺย ส๎วิเยยฺย วเทยฺย กาเลยฺย เยเปยฺย ยาเปยฺยาติ ส๎วาหิ นิสฺสา ชาคารมาวสเ ฯ

เตนาหา ภควา

เสาจเตฺต ปิ ชนา มมายิเต
น มหิ สเตฺต นิกฺขา ปริกฺขยา

---

๑ ม. ปร ปาริปูรี ฯ

(๑๙๐) អធិប្បាយពាក្យថា បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះទៀយ ត្រង់ពាក្យថា ដូច្នេះ គឺជាពាក្យភ្ជាប់បទ ជាពាក្យជាប់ចាក់ទងដោយបទ ជាពាក្យញុំាងបទឲ្យពេញ ជាពាក្យប្រដុំដោយអក្ខរៈ ជាបទសម្រួលព្យញ្ជនៈ ពាក្យថា ដូច្នេះ នេះ ជាលំដាប់នៃបទ ។ បុគ្គលឃើញ យល់ ថ្លឹង តិចារណា យល់ច្បាស់ ធ្វើឲ្យប្រាកដ ក្នុងវត្ថុដែលហួងហែង ដូច្នេះហើយ ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ ។ ពាក្យថា មិនគួរនៅគ្រប់គ្រងផ្ទះ គឺគប្បីកាត់បលិពោធ ក្នុងឃរាវាសគ្រប់យ៉ាង កាត់បលិពោធ ក្នុងបុត្តភរិយា កាត់បលិពោធក្នុងពួកញាតិ កាត់បលិពោធក្នុងមិត្តនិងអាមាត្យ កាត់បលិពោធក្នុងការសន្សំ ហើយកោរសក់នឹងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ(ចេញ) ចាកផ្ទះ ហើយបួសដោយតេទជាបុគ្គលមិនមានផ្ទះ ដល់នូវភាពមិនមានកង្វល់ ត្រាច់ទៅ នៃបនៅ សម្រេចសម្រាន្ត ប្រព្រឹត្ត រក្សា សម្រួល រស់នៅតែម្នាក់ឯង ហេតុនោះ (ទ្រង់ត្រាស់ថា) បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះទៀយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

ពួកជន រមែងសោកស្តាយ បំពោះវត្ថុដែលហួងហែង
ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ

វិនាភាវសន្តមេវិនំ

ឥតិ ឥស្សា ជាតារមារសេតិ ។

(๑๙๑) មរណេនបិ តំ បហីយតិ

យំ បុរិសោ មមយិទន្តិ មញ្ញតិ

ឯតម្បិ វិទិត្វា បណ្ឌិតោ

ន មមត្តាយ ន មេថ មាមកោ ។

(๑๙๒) មរណេនបិ តំ បហីយតីតិ មរណន្តិ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា[๑] ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយោ ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្សុបច្ឆេទោ ។ តត្ថ រូបតំ វេទនាតតំ សញ្ញាតតំ សង្ខារតតំ វិញ្ញាណតតំ ។ បហីយតីតិ បហីយតិ ឧបហីយតិ វិឧបហីយតិ អន្តរធាយតិ វិប្បលុជ្ជតិ ។ អាសិតម្បិ ហេតំ

បុត្តេ មច្ចុ វិឧបាន្តិ ភោគា

មច្ចោ វេ បុត្តតរំ ឧបាតិ

អសស្សតា ភោតិនោ កាមកាមិ

---

๑ ម. បរិភេទោ ខន្ធានំ ។

វត្ថុនេះ មានសភាពព្រោត់ប្រាសដោយពិត បុគ្គលយើញ
ដូច្នេះហើយ មិនគួរទៅគ្រប់គ្រងផ្ទះឡើយ ។

(១៩១) បុរសសំគាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធ-
បញ្ចកៈនោះ រមែងសាបសូន្យ ដោយមរណៈ បណ្ឌិត
ជាអ្នកពប់ពែន ដឹងច្បាស់ដំណើរនុ៎ះហើយ មិនគប្បីបង្អោន
ទៅក្នុងសេចក្តីហួងហែងឡើយ ។

(១៩២) អធិប្បាយពាក្យថា ខន្ធបញ្ចកៈនោះ រមែងសាបសូន្យ ដោយ
មរណៈ គ្រង់ពាក្យថា មរណៈ បានដល់ ការច្យុត ការឃ្លាត ការ
បែកធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ
ការដាក់ចោលសាកសព ការផ្តាច់បង់ជីវិតិន្ទ្រិយ ពាកសត្តនិកាយ
នោះ។ របស់សត្វទាំងឡាយនោះ។ ។ ពាក្យថា ខន្ធបញ្ចកៈនោះ
គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា សាបសូន្យ
គឺ សាបសូន្យ លះបង់ ចោះបង់ បាត់ទៅ វិនាសទៅ ។

សមដូចភាសិតនេះថា

កោគៈទាំងឡាយ រមែងលះបង់នូវសត្វក្នុងកាលមុន ក៏មាន
សត្វលះបង់កោគៈទាំងនោះ មុនជាងទៅទៀត ក៏មាន
នែអ្នកប្រាថ្នាកាម ពួកជនអ្នកមានកោគៈ មិនទៀងទេ

តស្មា ន សោចាមហំ សោកកាលេ

ទុនេតំ អាបូរតំ វេតំ ចង្គោ

អត្តំ តមេត្ថាន បលេតំ សុវិយោ

វិនិតា មយោ សត្តុកា លោកធម្មា

តស្មា ន សោចាមហំ សោកកាលេតំ ។

មរណោនមិ តំ មហីយតំ ។

(๑๙๓) យំ បុរិសោ មមយិនន្តិ មញ្ញតីតំ យន្តិ

រូបតតំ វេទនាតតំ សញ្ញាតតំ សង្ខារតតំ វិញ្ញាណ-

តតំ ។ បុរិសោតំ សង្ខា សមញ្ញា បញ្ញត្តិ លោក-

ភេហាភេ ធាមំ ធាមកម្មំ ធាមធេយ្យំ និរុត្តិ ព្យញ្ជនំ

អភិលាបោ ។ មមយិនន្តិ មញ្ញតីតំ តណ្ហាមញ្ញនាយ

មញ្ញតំ និដ្ឋិមញ្ញនាយ មញ្ញតំ មានមញ្ញនាយ មញ្ញតំ

កិលេសមញ្ញនាយ មញ្ញតំ ទុច្ចរិតមញ្ញនាយ មញ្ញតំ

បយោគមញ្ញនាយ មញ្ញតំ វិបាកមញ្ញនាយ មញ្ញតីតំ

យំ បុរិសោ មមយិនន្តិ មញ្ញតំ ។

ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ព្រះបន្ទូលនេះឯង លិបិ ព្រះអាទិត្យរះឡើងហើយអស្តង្គតទៅ នៃអ្នកជាសត្រូវ លោកធម៌ទាំងពួង ខ្ញុំដឹងច្បាស់ហើយ ព្រោះហេតុនោះ ខ្ញុំទើបមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។ ហេតុនោះ (ទ្រង់ត្រាស់ថា) ខន្ធបញ្ចកៈរមែងសាបសូន្យដោយមរណៈ ។

(๑๙๗) អធិប្បាយពាក្យថា បុរសសំគាល់នូវខន្ធបញ្ចកៈណាថា នេះរបស់អញ ត្រង់ពាក្យថា ខន្ធបញ្ចកៈណា គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ ពាក្យថា បុរស គឺ ការពោលឈ្មោះ បញ្ញត្តិ លោកវោហារ នាម អំពើរបស់នាម ពាក្យប្រទ្រង់ទុកនូវនាម ភាសា ព្យញ្ជនៈ ការហៅរក ។ ពាក្យថា សំគាល់ថា នេះរបស់អញ គឺសំគាល់ក្នុងការសំគាល់ដោយតណ្ហា សំគាល់ក្នុងការសំគាល់ដោយទិដ្ឋិ សំគាល់ក្នុងការសំគាល់ដោយមានះ សំគាល់ក្នុងការសំគាល់ដោយកិលេស សំគាល់ក្នុងការសំគាល់ដោយទុច្ចរិត សំគាល់ក្នុងការសំគាល់ដោយបរិយោគៈ សំគាល់ក្នុងការសំគាល់ដោយវិបាក ហេតុនោះ (ទ្រង់ត្រាស់ថា) បុរសសំគាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ។

(๑๙๔) ฯតមវ្ច វិនិត្វា[๑] បណ្ឌិតោតិ ฯតំ អាធិ-
ឆវំ ញត្វា ជានិត្វា តុលយិត្វា តីរយិត្វា វិភាវយិត្វា
វិភូតំ កត្វា មមត្តេស្វតិ ฯតមវ្ច វិនិត្វា ។ បណ្ឌិ-
តោតិ[๒] ពុទ្ធិមា ញាណី វិភាវី មេធាវីតិ ฯតមវ្ច វិ-
និត្វា[๓] បណ្ឌិតោ ។

(๑๙๕) ន មមត្តាយ នមេថ មាមកោតិ
មមត្តាតិ ទ្វេ មមត្តា តណ្ហាមមត្តញ្ច ទិដ្ឋិម-
មត្តញ្ច ។ បេ ។ ឥទំ តណ្ហាមមត្តំ ។ បេ ។ ឥទំ
ទិដ្ឋិមមត្តំ ។ មាមកោតិ ពុទ្ធមាមកោ ធម្មមាមកោ
សង្ឃមាមកោ សោ ភគវន្តំ មមាយតិ ភគវា តំ
បុគ្គលំ បរិក្ខណ្ហាតិ ។ រុឡ្ហំ ហោតំ ភគវតា យេ តេ
កិក្ខវេ កិក្ខូ កុហា ថទ្ធា[๔] លបា សង្កិ ខុដ្ឋឆ្ឆា
អសមាហិតា ន មេ តេ កិក្ខវេ កិក្ខូ មាមកា

---

๑ ម. ឯតំ វិទិត្វាន ។ ๒ ម. បណ្ឌិកោ ធីរោ បណ្ឌិកោ បញ្ញវា ។ ๓ ម. ឯតំ វិទិត្វាន ។
๔ ម. ពទ្ធា ។

(១៩៤) ពាក្យថា បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ គឺ ដឹង ស្គាល់ ថ្នឹង ត្រិះរិះ ពិចារណា ឈ្វេងយល់ ធ្វើឲ្យច្បាស់ជាក់នូវហេតុនុ៎ះ ក្នុងវត្ថុ ដែលហួសហែងពាំងឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) ដឹងច្បាស់ដំណើរនុ៎ះ ។ ពាក្យថា បណ្ឌិត គឺអ្នកមានប្រាជ្ញា មានញាណ មានបញ្ញា ភ្លឺច្បាស់ មានបញ្ញាធ្ងន់ឡាយ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតដឹងច្បាស់ដំណើរនុ៎ះ ។

(១៩៥) អធិប្បាយពាក្យថា ជាអ្នកពាប់អាន មិនគប្បីបង្អោនទៅក្នុងសេចក្តីហួសហែងទេ ត្រង់ពាក្យថា សេចក្តីហួសហែង បានដល់ សេចក្តីហួសហែង ២ គឺ សេចក្តីហួសហែងគឺតណ្ហា ១ សេចក្តីហួសហែងគឺទិដ្ឋិ ១ ។ បេ ។ នេះ សេចក្តីហួសហែងគឺតណ្ហា ។ បេ ។ នេះ សេចក្តីហួសហែងគឺទិដ្ឋិ ។ ពាក្យថា អ្នកពាប់អាន គឺអ្នកពាប់អានព្រះពុទ្ធ អ្នកពាប់អានព្រះធម៌ អ្នកពាប់អានព្រះសង្ឃ បុគ្គលនោះ តែងពាប់អានព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏ទ្រង់ពាប់អានបុគ្គលនោះ ។ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ហើយថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាអ្នកកុហក មានចិត្តរឹងត្អឹង ចរចាហួសហេតុ មានការជាប់ចំពាក់ ជាអ្នកឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនោះ មិនមែនពាប់អានតថាគតទេ

អបតតា ច តេ កិត្តី[1] ឥមស្មា ឆម្មវិនយា ឧ
ច តេ ឥមស្មឹ ឆម្មវិនយេ វុឌ្ឍិ វិរូឡ្ហិ វេបុល្លំ អាបជ្ជន្តិ
យេ ច ខោ តេ កិត្តវេ កិត្តិ ឯក្កមេ ឯល្លកា
ឯកា អឌ្ឍា[2] សុសមាហិតា តេ ខោ មេ កិត្តវេ
កិត្តិ មាមកា អនបតតា ច តេ កិត្តិ ឥមស្មា
ឆម្មវិនយា តេ ច ឥមស្មឹ ឆម្មវិនយេ វុឌ្ឍិ វិរូឡ្ហិ
វេបុល្លំ អាបជ្ជន្តិតំ ។

ឯក្កមេ ឯឌ្ឍា លភា សន្តិ ខុទ្ទទ្បា អសមាហិតា
ឧ តេ ឆម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ
ឯក្កមេ ឯល្លកា ឯកា អឌ្ឍា សុសមាហិតា
តេ វេ ឆម្មេ វិរូហន្តិ សម្មាសម្ពុទ្ធទេសិតេ ។

ឧ មមត្តាយ ឧមេឌ មាមកោតិ មាមកោ តណ្ហា-
មមត្តំ បហាយ និដ្ឋមមត្តំ បដិនិស្សដ្ឋត្តា មមត្តាយ

---

๑ ម. តេ កិត្តវេ កិត្តិ ។ ๒. ម. អឌ្ឍា ។

មួយទៀត កិកូ៎ពាំងនោះ ប្រាសចាកធម៌វិន័យនេះហើយ កិកូ៎ពាំងនោះ មិនដល់នូវការចំរើន លូតលាស់ ធំទូលាយ ក្នុងធម៌វិន័យនេះទេ ម្នាលកិកូ៎ពាំងឡាយ លុះតែពួកកិកូ៎ណា មិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាឆ្លាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ ម្នាលកិកូ៎ពាំងឡាយ កិកូ៎ពាំងនោះឯង ឈ្មោះថា អ្នកពាល់អានតថាគត មួយទៀត កិកូ៎ពាំងនោះ មិនប្រាសចាកធម៌វិន័យនេះទេ កិកូ៎ពាំងនោះ ដល់នូវសេចក្តីចំរើន លូតលាស់ ធំទូលាយ ក្នុងធម៌វិន័យនេះ ។

ពួកកិកូ៎ណា ជាអ្នកកុហក រឹងត្អឹង ចរចាហួសហេតុ មានការជាប់ចំពាក់ ឆ្មើងឆ្មៃ មានចិត្តមិនតាំងមាំ កិកូ៎ពាំងនោះ មិនលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធសំដែងទេ ពួកកិកូ៎ណា ជាអ្នកមិនកុហក មិនចរចាហួសហេតុ មានប្រាជ្ញាឆ្លាប់ខ្ជួន មិនរឹងត្អឹង មានចិត្តតាំងមាំល្អ កិកូ៎ពាំងនោះ ទើបលូតលាស់ ក្នុងធម៌ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ។

ពាក្យថា បណ្ឌិតជាអ្នកពាល់អាន មិនគប្បីបង្អាន់ក្នុងសេចក្តីហួនហែង ជានសេចក្តីថា បុគ្គលអ្នកពាល់អាន (ព្រះត្រៃបិដក) គប្បីលះចង់សេចក្តីហួនហែងគឺតណ្ហា រលាស់ចោលសេចក្តីហួនហែង គឺទិដ្ឋិ

ន ជនេយ្យ ន ទិនេយ្យ ន តន្តិន្នោ អស្ស

ន តប្បោ ណោ ន តយ្យញ្ញោ ន តនធម្មុត្តោ ន

តនាធិបតេយ្យោតំ ន មមត្តាយ ជនេថ មាមកោ ។

តេនាហ ភគវា

មរណេនបិ តំ បហីយតំ

យំ បុរិសោ មមយិនន្តិ មញ្ញតំ

ឯតម្បិ វិទិត្វា បណ្ឌិតោ

ន មមត្តាយ ជនេថ មាមកោតំ ។

(๑๙๖) សុបិនេន យថាបិ សង្គតំ

បដិពុទ្ធោ បុរិសោ ន បស្សតំ

ឯវម្បិ បិយាយិតំ ជនំ

បេតំ កាលកតំ ន បស្សតំ ។

(๑๙๗) សុបិនេន យថាបិ សង្គតន្តិ សង្គតំ សមាគ-

តំ សមាហិតំ សន្និបតិតន្តិ សុបិនេន យថាបិ សង្គតំ ។

ហើយមិនបង្អោនទៅ មិនបន្ថយទៅ ក្នុងសេចក្តីហួងហែង ជាអ្នកមិនតុនទៅរកសេចក្តីហួងហែងនោះ មិនងាកទៅរកសេចក្តីហួងហែងនោះ មិនឈមទៅរកសេចក្តីហួងហែងនោះ មិនចុះចិត្តស៊ប់ទៅរកសេចក្តីហួងហែងនោះ មិនយកសេចក្តីហួងហែងនោះជាធំ ហេតុនោះ (ទ្រង់ត្រាស់ថា) បណ្ឌិតជាអ្នកពប់រឥន មិនគប្បីបង្អោនទៅ ក្នុងសេចក្តីហួងហែង ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

បុរសសំគាល់ខន្ធបញ្ចកៈណាថា នេះរបស់អញ ខន្ធបញ្ចកៈនោះ រមែងសាបសូន្យដោយមរណៈ បណ្ឌិតជាអ្នកពប់រឥនជ្ញានដ៏ឆ្ងាស់ដំណើរទុំនេះហើយ មិនគប្បីបង្អោនទៅក្នុងសេចក្តីហួងហែងឡើយ ។

(๑๙๖) បុរសភ្លក់ឡើងហើយ មិនឃើញអារម្មណ៍ ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

(๑๙๗) ពាក្យថា អារម្មណ៍ដែលចួបប្រទះដោយការយល់សប្តិ យ៉ាងណា គឺចួបប្រទះ កប់ប្រសប់ រួមគ្នា ចួបជុំគ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) អារម្មណ៍ដែលចួបប្រទះ ដោយការយល់សប្តិ យ៉ាងណា ។

(๑๙๘) ปฐวีธาตุยา ปุริเสา ฯ ปสฺสทฺธีติ ยถา ปุริเสา สุปินกเตา จตฺตาริ ปสฺสทฺธิ สุริยา ปสฺสทฺธิ มหาสมุทฺทา ปสฺสทฺธิ สิเนรุปพฺพตราชา ปสฺสทฺธิ หตฺถี ปสฺสทฺธิ อสฺสา ปสฺสทฺธิ รถา ปสฺสทฺธิ ปตฺตี ปสฺสทฺธิ เสนาพฺยูหา ปสฺสทฺธิ อากาสภูมิยา ปสฺสทฺธิ วนภูมิยา ปสฺสทฺธิ ภูมิภูมิยา ปสฺสทฺธิ เทวตาภูมิยา ปสฺสทฺธิ ปฐวีธาตุยา กายิกา ปสฺสทฺธิ ปฐวีธาตุยา ฯ

(๑๙๙) ฌายี ปิยายิตพฺพา ฌานฺติ ฌายี ฌานาภิรตา ฯ ปิยายิตพฺพา ฌานฺติ ปิยายิตพฺพา มนาปายิตพฺพา ฌานา มาตรา ปิตรา ภาตรา ภคินิยา ปุตฺตา ธีตรา มิตฺตา อมจฺจา ญาติสาโลหิตา ภาตโร ฌานา ปิยายิตพฺพา ฌานา ฯ

(๒๐๐) เขมนฺติ ภยาภาวฏฺเน ปสฺสทฺธีติ เขมา วุฏฺฐิ เขมา ภาสิตา ฯ ปสฺสทฺธิ ฯ นิกฺกิเลสตา นิมิตฺตตา ฯ ปสฺสทฺธิ ฯ เขมนฺติ ปสฺสทฺธิ ฯ

เตรสหิ ภิกฺขูหิ

(๑๙๘) ពាក្យថា បុរសក្លាក់ឡើងហើយ មិនឃើញ សេចក្តីថា បុរសអ្នកយល់សប្តិឃើញព្រះចន្ទ្រ ឃើញព្រះអាទិត្យ ឃើញមហាសមុទ្រ ឃើញស្តេចភ្នំសិនេរុ ឃើញដំរី ឃើញសេះ ឃើញរថ ឃើញពលថ្មើដើរ ឃើញសេនាព្យូហៈ ឃើញសួនច្បារជាទីត្រេកអរ ឃើញព្រៃជាទីត្រេកអរ ឃើញផែនដីជាទីត្រេកអរ ឃើញស្រះបោក្ខរណីជាទីត្រេកអរ ក្លាក់ឡើងហើយ ក៏មិនឃើញអ្វីសោះ យ៉ាងណា ហេតុនោះ(ទ្រង់ត្រាស់ថា) បុរសក្លាក់ឡើងហើយមិនឃើញ ។

(๑๙๙) ពាក្យថា ក៏យ៉ាងនោះដែរ រមស់បទថា ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ គឺដាក់ចាត្តល់ដោយសេចក្តីឧបមា ។ ពាក្យថា ជនជាទីស្រឡាញ់ គឺជនដែលស្រឡាញ់ ដែលរាប់អាន គោរពដូចមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី បុត្តក្តី ធីតាក្តី មិត្រក្តី អាមាត្យក្តី ញាតិសាលោហិតក្តី ហេតុនោះ (ទ្រង់ត្រាស់ថា) ជនជាទីស្រឡាញ់ ក៏យ៉ាងនោះដែរ ។

(๒๐๐) ពាក្យថា បុគ្គលមិនឃើញជន ដែលធ្វើមរណកាលទៅកាន់បរលោកហើយ សេចក្តីថា ពួកជនស្លាប់ ធ្វើមរណកាលហើយ លោកហៅថា អ្នកទៅកាន់បរលោក ។ បុគ្គលមិនឃើញ មិនបួប មិនប្រទះ មិនបាន ឥតបាន ហេតុនោះ(ទ្រង់ត្រាស់ថា) មិនឃើញជន ដែលធ្វើមរណ-កាលទៅកាន់បរលោកហើយ ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

សុបិនេន យេថាបិ សន្ថុតំ
បដិពុទ្ធោ បុរិសោ ន បស្សតិ
ឯវម្បិ បិយោយិតំ ជនំ
បេតំ កាលកតំ ន បស្សតីតិ ។

(๒๐๑) និដ្ឋាបិ សុតាបិ តេ ជនា
យេសំ ជាមមិទំ បវុច្ចតិ
ជាមមេវាវសិស្សតិ
អក្ខេយ្យំ បេតស្ស ជន្តុនោ ។

(๒๐๒) និដ្ឋាបិ សុតាបិ តេ ជនាតិ និដ្ឋាតិ យេ ចក្ខុវិញ្ញេយ្យានភិសម្ភុតា ។ សុតាតិ យេ សោតវិញ្ញេយ្យានភិសម្ភុតា ។ តេ ជនាតិ ខត្តិយោ ច ព្រាហ្មណោ ច វេស្សោ ច សុទ្ទោ ច គហដ្ឋោ ច បព្ពជិតោ ច ទេវា ច មនុស្សា ចាតិ និដ្ឋាបិ សុតាបិ តេ ជនា ។

(๒๐๓) យេសំ ជាមមិទំ បវុច្ចតីតិ យេសន្តិ យេសំ ខត្តិយានំ ព្រាហ្មណានំ វេស្សានំ សុទ្ទានំ គហដ្ឋានំ បព្ពជិតានំ ទេវានំ មនុស្សានំ ។ ជាមន្តិ សង្ខា សមញ្ញា បញ្ញត្តិ លោកវោហារោ ជាមំ

បុរសស្លាក់ខ្សែធ្នូហើយ មិនឃើញការម្ចាស់ដែលចួបប្រទះ ដោយការយល់សប្តិ យ៉ាងណា បុគ្គលមិនឃើញ ជនជាទីស្រឡាញ់ ដែលឆ្លើមរណកាល ទៅកាន់បរលោកហើយ ក៏យ៉ាងនោះដែរ ។

(២០១) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជននោះ គេឃើញខ្លះ មិនខ្លះ នាមហ្នឹងឯងរបស់សត្វទៅកាន់បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។

(២០២) អធិប្បាយពាក្យថា ពួកជននោះ គេឃើញខ្លះ មិនខ្លះ ត្រង់ពាក្យថា គេឃើញ គឺពួកជនណា ដែលចួបប្រទះ ដោយចក្ខុវិញ្ញាណ ។ ពាក្យថា មិន គឺពួកជនណា ដែលចួបប្រទះ ដោយសោតវិញ្ញាណ ។ ពាក្យថា ពួកជននោះ គឺក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា និង មនុស្ស ហេតុនោះ (ត្រង់ត្រាស់ថា) ពួកជននោះ គេឃើញខ្លះ មិនខ្លះ ។

(២០៣) អធិប្បាយពាក្យថា នាមនេះ របស់ពួកជនណា ដែលគេតែងពោល ត្រង់ពាក្យថា របស់ពួកជនណា គឺរបស់ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិត ទេវតា មនុស្សណា ។ ពាក្យថា នាម គឺការរាប់ ឈ្មោះ បញ្ញត្តិ លោកវោហារ នាម

ฉนฺทราคปฺปหานาย ฉนฺทราคปฺปหานาย ฯ ปหีนตณฺหา ฯ ปหีนตณฺหาย กามตณฺหาย ภวตณฺหาย วิภวตณฺหาย ปหีนตณฺหาย กามตณฺหาย ภวตณฺหาย วิภวตณฺหาย

អំពើរបស់នាម ពាក្យទ្រទ្រង់នូវនាម ភាសា ព្យញ្ជនៈ ការហៅរក ។ ពាក្យថា គេតែងពោល គឺ គេតែងសំដែង តែងនិយាយ តែងបំភ្លឺ តែងបញ្ចេញ ហេតុនោះ (ទ្រង់ត្រាស់ថា) នាមនេះ របស់ពួកជនណា ដែលគេតែងពោល ។

(២០៤) ពាក្យថា នាមហ្នឹងឯងដែលគួរហៅបាន រមែងសល់នៅ សេចក្តីថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលឃ្លាតចេញ លះចេញស្រឡះ ផ្តាច់បង់ វិនាស តែនាមរមែងសល់នៅ ។ ពាក្យថា គួរហៅបាន គឺ គួរពោល សំដែង បំភ្លឺ បញ្ចេញបាន ហេតុនោះ (ទ្រង់ត្រាស់ថា) នាមហ្នឹងឯង ដែលគួរហៅបាន រមែងសល់នៅ ។ ពាក្យថា ទៀកាន់បរលោក របស់បទថា របស់សត្វទៀកាន់បរលោក គឺ សត្វស្លាប់ ឆ្លើមរណកាលហើយ ។ ពាក្យថា របស់សត្វ គឺរបស់សត្វនេះ មាណព បុរស បុគ្គល សត្វមានជីវៈ សត្វមានជាតិ សត្វមានជរា សត្វទៅដោយឥន្ទ្រិយ សត្វមានជាតិអំពីមនុស្ស ហេតុនោះ (ទ្រង់ត្រាស់ថា) របស់សត្វទៀកាន់បរលោក ដែលគួរហៅបាន ។ ហេតុនោះ ព្រះមានព្រះភាគ ត្រាស់ថា

> នាមនេះ របស់ពួកជនណា ដែលគេតែងពោល ពួកជន
> នោះ គេយើញខ្លះ ឮខ្លះ នាមហ្នឹងឯងរបស់សត្វ ទៀកាន់
> បរលោក ដែលគេគួរហៅបាន រមែងសល់នៅ ។

(๒๐๔) សោកាមរតិនោមច្ចុ

ន ឥហត្ថិ តិន្ទ្ធោ មមាយិតេ

តស្មា មុនយោ បរិក្កមា

ហិត្វា អបរិសុ ខេមទស្សិនោ ។

(๒๐๖) សោកមរតិនោមច្ចុ ន ឥហត្ថិ តិន្ទ្ធោ មមាយិតេតិ សោកោតិ ញាតព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោ សោកោ អន្តោ បរិសោកោ អន្តោជាលោ អន្តោបរិជាលោ ចេតសោ បរិដ្ឌាយនា ចោមនស្សំ សោកសល្លំ ។ បរិទេវោតិ ញាតព្យសនេន វា ផុដ្ឋស្ស ។ បេ ។ ទិដ្ឋិព្យសនេន វា

(๒๐๕) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្សឹកខ្សួល នឹងសេចក្តីកំណាញ់ ក្នុងវត្ថុ ដែលហួងហែង ព្រោះហេតុនោះ មុនិពាំងឡាយ ជាអ្នកឃើញសេចក្តីក្សេម ឃ្លាតប្រព្រឹត្តលះបង់សេចក្តីហួងហែងចេញ ។

(๒๐๖) អធិប្បាយពាក្យថា ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់សេចក្តីសោក សេចក្តីខ្សឹកខ្សួល នឹងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ត្រង់ពាក្យថា សេចក្តីសោកគឺការសោក ការសោកស្តាយ ភាពនៃចិត្តសោកស្តាយ សោកខាងក្នុង ស្តាយស្រណោះខាងក្នុង ក្តៅក្រហាយខាងក្នុង ក្តៅពោលកលខាងក្នុង ជ្រប់ ស្រពោនចិត្ត ទោមនស្ស សរគឺសោក របស់សត្វ ដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី សេចក្តីវិនាសភោគៈប៉ះពាល់ក្តី សេចក្តីវិនាសគឺរោគប៉ះពាល់ក្តី សេចក្តីវិនាសសីលប៉ះពាល់ក្តី សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីខ្សឹកខ្សួល គឺការយំ ការយំរឿបរាប់ អាការយំ អាការយំរឿបរាប់ ភាពនៃការយំ ភាពនៃការយំរឿបរាប់ ការនិយាយ ការពោលឥតប្រយោជន៍ ការពោលរអើរអៃ ការពោលរឿយៗ អាការដាក់ពោលរឿយៗ ភាពនៃការពោលរឿយៗ របស់សត្វដែលត្រូវសេចក្តីវិនាសញាតិប៉ះពាល់ក្តី ។ បេ ។

ជុដ្ឋស្ស អញ្ញតរញ្ញតរេន វា ព្យសនេន សមន្នា-
គតស្ស អញ្ញតរញ្ញតរេន វា ទុក្ខធម្មេន វា ផុដ្ឋស្ស
អានេរៀ បរិនេរៀ អានេរិយា បរិនេរិយា អានេរិតត្តំ
បរិនេរិតត្តំ វា បលាបោ វិប្បលាបោ លាលប្បោ
លាលប្បាយនា លាលប្បាយិតត្តំ ។ មច្ចរិយន្តិ បញ្ច
មច្ចរិយានិ អាវាសមច្ចរិយំ កុលមច្ចរិយំ លាភមច្ចរិយំ
វណ្ណមច្ចរិយំ ធម្មមច្ចរិយំ យំ ឯវរូបំ មច្ចរិយំ មច្ច-
រាយនា មច្ចរាយិតត្តំ វេវិច្ឆំ កទរិយំ កដុកញ្ចុកតា
អគ្គហិតត្តំ ចិត្តស្ស អយំ វុច្ចតិ មច្ចរិយំ ។ អបិច ទ្វេ-
មច្ចរិយានិបិ មច្ចរិយំ ជាតុមច្ចរិយំបិ មច្ចរិយំ អាយតនម-
ច្ចរិយំបិ មច្ចរិយំ តាវោ អយំ វុច្ចតិ មច្ចរិយំ ។ តេជោ
វុច្ចតិ តណ្ហា យោ រាគោ សារាគោ ។ បេ ។ អភិជ្ឈា
លោភោ អកុសលមូលំ ។ មមត្តាតិ ទ្វេ មមត្តា
តណ្ហាមមត្តញ្ច ទិដ្ឋិមមត្តញ្ច ។ បេ ។ អយំ តណ្ហា-
មមត្តំ ។ បេ ។ អយំ ទិដ្ឋិមមត្តំ ។ មមាយិតវត្ថុ-
អច្ចេនសន្តិំ នោបិ សោចន្តិ អច្ចិដ្ឋន្តេបិ សោចន្តិ
អច្ចន្តេបិ សោចន្តិ មមាយិតវត្ថុវិបរិណាមសន្តិំ នោបិ

សេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ប្រកបដោយសេចក្តីវិនាសណាមួយក្តី ទុក្ខ-
ធម៌ណាមួយប៉ះពាល់ក្តី ។ ពាក្យថា សេចក្តីកំណាញ់ ជាន់ដល់សេចក្តី
កំណាញ់ ៥ យ៉ាង គឺសេចក្តីកំណាញ់អាវាស ១ សេចក្តីកំណាញ់ត្រកូល ១
សេចក្តីកំណាញ់លាភ ១ សេចក្តីកំណាញ់វណ្ណៈ ១ សេចក្តីកំណាញ់ធម៌ ១
សេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃការកំណាញ់ សេចក្តីប្រាថ្នា
ផ្សេងៗ ស្វាក្រន្ទឹះ ភាពនៃចិត្តរួញ ភាពនៃការមិនយកចិត្តគេ ណា
មានសភាពយ៉ាងនេះ នេះ ហៅថា សេចក្តីកំណាញ់ ។ មួយទៀត
សេចក្តីកំណាញ់ខន្ធ ក៏ឈ្មោះថាសេចក្តីកំណាញ់ សេចក្តីកំណាញ់ធាតុ
ក៏ឈ្មោះថា សេចក្តីកំណាញ់ សេចក្តីកំណាញ់អាយតនៈ ក៏ឈ្មោះ
ថាសេចក្តីកំណាញ់ ការគិតតែកាន់យក នេះលោកហៅថា សេចក្តី
កំណាញ់ ។ តណ្ហា លោកហៅថា ការចង់បាន ជាន់ដល់តម្រេក
តម្រេកខ្លាំង ។បេ។ ការសំឡឹងរំពៃ លោភៈ អកុសលមូល ។ ពាក្យថា
ការហួងហែង ជាន់ដល់ការហួងហែង ៤ គឺ ការហួងហែងគឺតណ្ហា ១
ការហួងហែងគឺទិដ្ឋិ ១ ។បេ។ នេះការហួងហែងគឺតណ្ហា ។បេ។ នេះ
ការហួងហែងគឺទិដ្ឋិ ។ ពួកជនមានសេចក្តីរង្កៀស ដោយការដណ្តើម
យកវត្ថុដែលហួងហែង សោកស្តាយក៏មាន សោកស្តាយវត្ថុដែលគេកំពុង
ដណ្តើមយក ក៏មាន សោកស្តាយវត្ថុដែលគេដណ្តើមយកហើយ ក៏មាន
ពួកជន មានសេចក្តីរង្កៀសដោយការប្រែប្រួល នៃវត្ថុដែលហួងហែង

សោចន្តំ វិបរិណាមន្តេបិ សោចន្តិ វិបរិណាតេបិ
សោចន្តិ ។ មមាយិតវត្ថុអច្ឆេទសង្កិនោបិ បរិទេវន្តិ
អច្ឆិជ្ជន្តេបិ បរិទេវន្តិ អច្ឆិន្នេបិ បរិទេវន្តិ ។ មមាយិ-
តវត្ថុវិបរិណាមសង្កិនោបិ បរិទេវន្តិ វិបរិណាមន្តេបិ
បរិទេវន្តិ វិបរិណាតេបិ បរិទេវន្តិ ។ មមាយិតវត្ថុំ
រក្ខន្តិ គោបេន្តិ បរិក្ខណ្ហន្តិ មមាយិតន្តិ មច្ចុកាយន្តិ ។
មមាយិតស្មឹ វត្ថុស្មឹ សោចន្តិ សោកំ ន ជហន្តិ
បរិទេវំ ន ជហន្តិ មច្ចុរាយំ ន ជហន្តិ តេនំ ន
ជហន្តិ ឆម្ភជហន្តិ ន វិនោទេន្តិ ន ព្យន្តីករោន្តិ
ន អនភាវង្គមេន្តីតិ សោកបរិទេវមច្ចុំ ន ជហន្តិ
តំន្វា មមាយិតេ ។

(๒๐๗) តស្មា មុនយោ បរិក្កមំ ហិត្វា
អចរីសុ ខេមទស្សិនោតិ តស្មាតិ តស្មា
តំការណា តំហេតុ តប្បច្ចយោ តំនិទានា ឯតំ

រមែងសោកស្តាយ ក៏មាន សោកស្តាយវត្ថុដែលកំពុងប្រែប្រួល ក៏មាន សោកស្តាយវត្ថុដែលប្រែប្រួលហើយ ក៏មាន ។ អ្នកមានសេចក្តីរង្កៀស ដោយការដណ្តើមយកវត្ថុដែលហួងហែង ខ្វែកខ្វួល ក៏មាន ខ្វែកខ្វួលនឹងវត្ថុដែលគេកំពុងដណ្តើមយកក៏មាន ខ្វែកខ្វួលនឹងវត្ថុដែលគេដណ្តើមយកហើយក៏មាន អ្នកមានសេចក្តីរង្កៀសដោយការប្រែប្រួលនៃវត្ថុដែលហួងហែង ខ្វែកខ្វួលក៏មាន ខ្វែកខ្វួលនឹងវត្ថុដែលកំពុងប្រែប្រួលក៏មាន ខ្វែកខ្វួលនឹងវត្ថុ ដែលប្រែប្រួលហើយក៏មាន ។ ពួកជនរមែងរក្សា គ្រប់គ្រងកួចកាន់ ហួងហែង កំណាញ់វត្ថុដែលហួងហែង ។ ពួកជនរមែងសោកស្តាយ វត្ថុដែលហួងហែង មិនលះបង់សេចក្តីសោក មិនលះបង់សេចក្តីខ្វែកខ្វួល មិនលះបង់សេចក្តីកំណាញ់ មិនលះបង់ មិនលះចោល មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យដល់នូវភាវមិនកើតមានសេចក្តីប្រាថ្នា ហេតុនោះ (ទ្រង់ត្រាស់ថា) ពួកជនអ្នកប្រាថ្នា រមែងមិនលះបង់នូវសេចក្តីសោក សេចក្តីខ្វែកខ្វួល និងសេចក្តីកំណាញ់ ក្នុងវត្ថុដែលហួងហែង ។

(๒๐๗) អធិប្បាយពាក្យថា ព្រោះហេតុនោះ មុនិចាំនឹងក្លាយជាអ្នកឃើញសេចក្តីក្សេម បានប្រព្រឹត្ត លះបង់សេចក្តីហួងហែងចេញ ទ្រង់ពាក្យថា ព្រោះហេតុនោះ គឺព្រោះដូច្នោះ ព្រោះដំណើរនោះ ព្រោះហេតុនោះ ព្រោះបច្ច័យនោះ ព្រោះនិទាននោះ

អានេត្វាំ សម្ប្បុប្ផិតោ មមត្តេសុតំ តស្មា ។ មុនយោតំ មោនំ វុច្ចតិ ញាណំ យោ បញ្ញា បជា-ននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ តេន ញាណេន សមន្នាគតា មុនយោ មោនប្ប-ត្តា ។ តីណិ មោនេយ្យានិ កាយមោនេយ្យំ វចី-មោនេយ្យំ មនោមោនេយ្យំ ។ បេ ។ សង្គជាលមតិក្ក សោ មុនិ ។ បរិក្ខយោតំ ទ្វេ បរិក្ខយា តណ្ហា-បរិក្ខយោ ច ទិដ្ឋិបរិក្ខយោ ច ។ បេ ។ អយំ តណ្ហាបរិក្ខយោ ។ បេ ។ អយំ ទិដ្ឋិបរិក្ខយោ ។ មុនយោ តណ្ហាបរិក្ខយំ បហាយ ទិដ្ឋិបរិក្ខយំ បដិ-និស្សដ្ឋត្តា អចវីសុ វិចវីសុ[1] ឥរយីសុ វត្តីសុ ថាលវី-សុ យបីសុ យាបីសុ ។ ខេមធស្សីតោតំ ខេមំ វុច្ចតិ អមតំ និព្ពានំ យោ សោ សព្ពសង្ខារសមថោ សព្ពូប-ធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្ពា-នំ ។ ខេមធស្សីនោតំ ខេមធស្សីនោ តាណធស្សីនោ

๑ ម. វិហរីសុ ។

